# អ្នកនាំសារ

The Messenger

33

ខែមេសា ឆ្នាំ២០០៦- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៏កាតូលិកប៉ុណ្ណោះ



## ព្រះយេស៊ូបូជាព្រះជន្មដើម្បីយើង !



អគារសិក្សាថ្មី ចំណងដៃយុវសិស្សក្រីក្រ

ទំព័រ ៦



យុវវ័យ និងការឈានដល់អាពាហ៍ពិពាហ៍

ទំព័រ ៨

មណ្ឌលពន្លឺនៃមេត្តាទទួលកុមារពិការ

ទំព័រ ១១

## តើសប្ដាហ៍ពិសិដ្ឋជាអ្វី ?



Photo: DR

គឺជាសប្ដាហ៍ចុងក្រោយនៃរដូវអប់រំពិសេស ឬរដូវ ៤០ថ្ងៃ។ សប្ដាហ៍នេះចាប់ផ្ដើមនៅថ្ងៃអាទិត្យ ព្រះយេស៊ូយាងចូលទីក្រុងយេរូសាឡឹម (បុណ្យហែស្លឹក) ដែលប្រជាជនអ៊ីស្រាអែលទាំងអស់ទទួលស្វាគមន៏ព្រះអង្គដូចជាស្ដេចមួយអង្គដែលពួកគេកំពុងទន្ទឹងរង់ចាំប្រកបដោយសិរីកិត្តិយសយ៉ាងប្រសើរនោះ។ ហើយព្រះសហគមន៍ធ្វើពិធីនេះដែរ ដោយមានរៀបចំកាត់ស្លឹកជាច្រើន ហើយម្នាក់ៗ កាន់ស្លឹកនោះនៅក្នុងដៃរៀងៗខ្លួនចូលទៅក្នុងព្រះវិហារដើម្បីរម្លឹកដល់ព្រះយេស៊ូ។ តាមព្រះសហគមន៏ខ្លះ នៅក្នុងសប្ដាហ៍នេះ មានរៀបចំកម្មវិធីអធិដ្ឋានពិសេសរៀងរាល់ថ្ងៃ។ យើងអាចនិយាយថាជាសប្ដាហ៍ ដែលព្រះយេស៊ូធ្វើដំណើរទៅរកសេចក្ដីស្លាប់នៅលើឈើឆ្កាង ហើយព្រះជាម្ចាស់បានប្រោសព្រះអង្គ ឱ្យមានព្រះជន្មរស់ឡើងវិញតាមរបៀបថ្មី ដោយព្រះវិញ្ញាណដ៏វិសុទ្ធប្រកបដោយសិរីរុងរឿងដ៏ប្រសើរ។

**តើនៅក្នុងសប្ដាហ៍នេះមានអ្វីកើតឡើងខ្លះជាមួយព្រះយេស៊ូ ?**

នៅថ្ងៃព្រហស្បតិ៍ពិសិដ្ឋ ព្រះយេស៊ូធ្វើពិធីជប់លៀងចុងក្រោយរួមជាមួយក្រុមគ្រីស្ដទូត។ ក្រោយពេលពិធីជប់លៀង ព្រះយេស៊ូត្រូវគេចាប់នៅសួនច្បារកេសេម៉ានី ដោយមានការចង្អុលបង្ហាញពីសំណាក់លោក យូដាសអ៊ីស្ការ៉ាយុទ ជាសាវ័កដែលក្បត់ព្រះអង្គ។ នៅថ្ងៃសុក្រ ព្រះអង្គត្រូវគេកាត់ទោសប្រហារជីវិតដោយឆ្កាងនៅលើឈើឆ្កាង។ ហើយព្រះអង្គក៏សុគតនៅថ្ងៃនេះតែម្ដង។ នៅរាត្រីថ្ងៃសៅរ៍ ព្រះជាម្ចាស់បានប្រោសឱ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ប្រកបដោយសិរីរុងរឿងប្លែកពីមុន។ នេះគឺជារាត្រីបុណ្យចម្លង។

លី សុវណ្ណា



## ថ្ងៃទី ២៦ មីនា

ថ្ងៃអាទិត្យទី ៤ ក្នុងរដូវអប់រំពិសេស

### “ព្រះជាម្ចាស់ស្រលាញ់មនុស្សលោកខ្លាំងណាស់”

(យហ ៣,១៤-២១)

នៅពេលព្រះយេស៊ូសោយទិវង្គត ក្រុមសាវ័កវិលវល់ក្នុងចិត្ត និងខកចិត្តជាខ្លាំងដោយស្មានថា ព្រះជាម្ចាស់លះបង់ព្យាការីយេស៊ូ ដែលពួកគេសង្ឃឹមថា ជាព្រះគ្រីស្ដ ដែលយាងមករំដោះស្រុកគេ។ រយៈពេលយូរឆ្នាំក្រោយមក លោកយ៉ូហានជាសាវ័កដែលព្រះយេស៊ូស្រឡាញ់ ក៏រិះគិតយ៉ាងជ្រៅអំពីអត្ថន័យនៃឃាតកម្មដ៏ឃោរឃៅនោះ។ លោកយល់ឃើញថា ព្រះយេស៊ូមិនបរាជ័យដូចដែលគេស្មានពីមុនដំបូងនោះទេ នៅពេលដែលព្រះអង្គរងទុក្ខលំបាក ទ្រង់បានសម្ដែងសេចក្ដីស្រឡាញ់របស់ព្រះបិតាចំពោះមនុស្សលោកទៅវិញទេ ព្រះអង្គក៏ស្រឡាញ់ព្រះបិតាក្នុងនាមយើងផងដែរ។ ហេតុនេះហើយបានជាយើងជាគ្រីស្ដបរិស័ទ ផ្ញើជីវិតទាំងស្រុងទៅលើព្រះយេស៊ូ ដែលចម្លងយើងទៅកាន់ព្រះបិតា។ ដោយសារព្រះយេស៊ូ ព្រះអង្គសម្ដែងឱ្យយើងដឹងថា ព្រះជាម្ចាស់រួមសាមគ្គីជាមួយអស់អ្នកដែលរងទុក្ខវេទនាតាំងពីដើមរៀងមក។

ជួនកាលយើងឆ្ងល់ ដោយឃើញអំពើហិង្សាគ្រប់យ៉ាង ដោយឃើញមនុស្សពាលប្រព្រឹត្តអំពើបាប យើងប្រហែលឮគេនិយាយថា បើមានព្រះជាម្ចាស់មែន ហេតុអ្វីព្រះអង្គមិនឃាត់ខ្មែរក្រហម កុំឱ្យធ្វើបាបប្រជាជនកម្ពុជា ? ហេតុអ្វីព្រះអង្គមិនការពារអ្នកតូចតាចដែលត្រូវអ្នកធំជិះជាន់ធ្វើបាប ? ធម្មតាយើងស្រមៃថា ព្រះជាម្ចាស់មានឫទ្ធានុភាពខ្លាំងក្លា និងអាចធ្វើអ្វីក៏បាន។ រីឯព្រះយេស៊ូវិញ ព្រះអង្គក៏សម្ដែងឱ្យយើងដឹងថា ព្រះអង្គស្រឡាញ់យើងរហូតយាងមករួមទុក្ខជាមួយយើង។ ព្រះអង្គឈ្នះហិង្សាដោយសេចក្ដីស្រឡាញ់ មិនមែនដោយបំផ្លាញអ្នកប្រព្រឹត្តអំពើហិង្សាទេ។ ពេលយើងគូរសញ្ញាឈើឆ្កាងលើខ្លួនយើង យើងនឹកពីព្រះហឫទ័យស្រឡាញ់ដ៏លើសលប់របស់ព្រះបិតាចំពោះយើង និងព្រះហឫទ័យស្រឡាញ់របស់ព្រះយេស៊ូចំពោះព្រះបិតាក្នុងនាមយើងដែរ។

## ថ្ងៃទី ២ មេសា

ថ្ងៃអាទិត្យទី ៥ ក្នុងរដូវអប់រំពិសេស

### “បើគ្រាប់ស្រូវងាប់ វានឹងបង្កើតបានផលច្រើន...”

(យហ ១២,២០-៣៣)

លោកយ៉ូហានគឺជាសាវ័កដែលព្រះយេស៊ូស្រឡាញ់ តែងតែពន្យល់ថា នៅពេលព្រះយេស៊ូសោយទិវង្គតលើឈើឆ្កាង គឺព្រះអង្គ “ទទួលសិរីរុងរឿង” ឬ “សម្ដែងសិរីរុងរឿងរបស់ព្រះបិតា”។ នៅពេលព្រះអង្គត្រូវអាម៉ាស យ៉ាងខ្លាំងបំផុត ព្រះអង្គសម្ដែងជម្រៅនៃព្រះហឫទ័យព្រះអង្គ។ ព្រះយេស៊ូខ្លាចការឈឺចុកចាប់ ព្រះអង្គក៏ខ្លាចសេចក្ដីស្លាប់ដែរ ហើយក៏ចង់ជៀសវាងកុំឱ្យកើតទុក្ខ ដូចមនុស្សឯទៀតៗទាំងអស់ផងដែរ។ ប៉ុន្តែនៅពេលនោះ ព្រះអង្គផ្ញើជីវិតទាំងស្រុងទៅលើព្រះបិតាដោយព្រះហឫទ័យស្រឡាញ់។

សព្វថ្ងៃបងប្អូនខ្មែរជាច្រើននាក់ក៏ចង់ស្វែងរកព្រះយេស៊ូដូចជនជាតិក្រិកពីដើមដែរ។ គ្រីស្ដបរិស័ទយើងនាំគេទៅកាន់ព្រះយេស៊ូ ដូចលោកភីលីប និងលោកអន់ដ្រេពីដើម។ ប្រសិនបើយើងសុខចិត្តលះបង់ប្រយោជន៏ផ្ទាល់ខ្លួនសម្រាប់ពួកគេ គឺ“បូជាជីវិត” ដូចព្រះយេស៊ូ ទើបគេអាចស្គាល់ព្រះអង្គបាន។ មានតែសេចក្ដីស្រឡាញ់យ៉ាងស្មោះមួយមុខប៉ុណ្ណោះ ដែលអាចបង្កើតផល គឺនាំឱ្យគេស្គាល់... ...ព្រះអង្គបាន។ ចំណេះដឹងអំពី គម្ពីរ ប្រាជ្ញា និងសំនួនវោហារក្នុងការឃោសនា មិនអាចបង្កើតផលផ្លែដែលស្ថិតស្ថេរបានឡើយ។ យើងសុខចិត្តឱ្យគេធ្វើបាប ដើម្បីបានផលទៅវិញ។

## ថ្ងៃទី ៩ មេសា ថ្ងៃគោរពព្រះយេស៊ូដែលរងទុក្ខលំបាក

### “អប្បា! សូមឱ្យបានសម្រេចតាមព្រះហឫទ័យព្រះអង្គ...”

(មក ១៤,១-១៥)

គ្រីស្ដបរិស័ទពីដើមរៀបរាប់អំពីទុក្ខលំបាករបស់ព្រះយេស៊ូ ដោយមានគោលបំណងចង់ពន្យល់អំពីមូលហេតុ លោកគ្រូយេស៊ូដែលគេគោរពទុកដូចជាព្រះគ្រីស្ដនោះ ត្រូវតែរងទុក្ខលំបាក យ៉ាងសែនអាម៉ាសដូច្នេះ។ ហេតុនេះ គេរៀបរាប់អំពីទុក្ខលំបាកនេះ ដោយយោងសេចក្ដីជាច្រើន ពីព្រះគម្ពីររបស់គេ គឺពីគម្ពីរ ដែលយើងហៅថា “គម្ពីរសម្ព័ន្ធមេត្រីចាស់” ដែលគេយល់ថា បានបង្ហាញអំពីគម្រោងការណ៏របស់ព្រះជាម្ចាស់។ ព្រះយេស៊ូរងទុក្ខ តាមគម្រោងការណ៏របស់ព្រះជាម្ចាស់នោះ គឺព្រះអង្គប្រៀបដូចជាមនុស្សសុចរិត មនុស្សសុភាពរាបសា និងដូចជាអ្នកបម្រើរបស់ព្រះជាម្ចាស់ដែលឈ្នះភាពឃោរឃៅរបស់មនុស្សដោយសេចក្ដីស្រឡាញ់។

លោកម៉ាកុសរៀបរាប់សេចក្ដីនេះ ដោយពណ៌នាថា គេលះបង់ព្រះអង្គគ្រប់គ្នា សូម្បីតែព្រះបិតាក៏ហាក់ដូចជាលះបង់ព្រះអង្គដែរ។ តែក្រោយពេលដែលព្រះអង្គសោយទិវង្គតរួច មេទាហានរ៉ូម៉ាំងប្រកាសជំនឿថា “លោកពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន”។ ព្រះយេស៊ូសម្ដែងឋានៈរបស់ព្រះអង្គដោយរងទុក្ខលំបាកដូច្នេះ។

ពេលយើងអាន ឬស្ដាប់អត្ថបទនេះ យើងនឹកគិតថា រឿងព្រះយេស៊ូនេះ ក៏ជារឿងទុក្ខលំបាករបស់មនុស្សជាច្រើននាក់សព្វថ្ងៃនេះដែរ ដូចគ្រីស្ដបរិស័ទម្នាក់ថ្លែងថា: “ព្រះយេស៊ូនៅតែរងទុក្ខលំបាករហូតដល់ថ្ងៃចុងក្រោយបំផុត យើងមិនត្រូវដេកលក់នៅពេលព្រះគ្រីស្ដរងទុក្ខលំបាកដូច្នេះទេ”។

## ថ្ងៃទី ១៦ មេសា បុណ្យចម្លង

### “លោកឃើញ ហើយជឿ...”

(យហ ២០,១-៩)

នៅព្រឹកថ្ងៃអាទិត្យ នាងម៉ារី ម៉ាដាឡា លោកសិលា និងលោកយ៉ូហានទៅផ្នូរព្រះយេស៊ូ។ ពួកគេទៅរកសពមនុស្សស្លាប់ម្នាក់បានជាគេមើលសពមិនឃើញ។ ចិត្តគេ “នៅងងឹតនៅឡើយ” ដូចជាមេឃ បានសេចក្ដីថា គេមិនទាន់មានជំនឿទេ។ លោកយ៉ូហានជាសាវ័កដែលព្រះយេស៊ូស្រលាញ់រត់លឿនជាងលោកសិលា ហើយទៅដល់ផ្នូរមុន ព្រោះគាត់ស្រលាញ់ព្រះអង្គខ្លាំងជាង តែគាត់ទុកឱ្យប្រធានក្រុមសាវ័កចូលមុនដោយចង់គោរពមុខងារ លោកសិលាជាសាក្សីទី១។ លោកយ៉ូហានក៏ដូចជាលោកសិលាដែរ គឺពុំឃើញអ្វីផ្សេងក្រៅពីក្រណាត់បត់ស្រួលបួល ប៉ុន្តែលោក“ជឿ”។ អ្នកនិពន្ធមិនបញ្ជាក់ថា ជឿលើអ្វីទេ គឺលោកជឿថាទោះបីជាលោកមិនឃើញសពព្រះយេស៊ូក្ដី ក៏គាត់ផ្ញើជីវិតលើព្រះអង្គ ដែលទទួលព្រះជន្មដ៏រុងរឿង។ គាត់មិនឃើញព្រះយេស៊ូ ដោយផ្ទាល់នឹងភ្នែកទេ គឺឃើញដោយសារជំនឿ និងដោយសេចក្ដីស្រឡាញ់វិញ។

ចំពោះយើងសព្វថ្ងៃ ក៏មើលពុំឃើញព្រះយេស៊ូដែរ ប៉ុន្តែយើងជឿថា ព្រះអង្គគង់នៅជាមួយយើង ព្រះអង្គក៏អង្វរព្រះបិតាឱ្យយើងដែរ ព្រះអង្គនាំយើងឆ្ពោះទៅកាន់ព្រះបិតា។

សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា !

## ព្រះជាម្ចាស់ស្រឡាញ់យើង!

ក្នុងឱកាសបុណ្យព្រះយេស៊ូមានព្រះជន្មឡើងវិញឆ្នាំនេះ អ្នកនាំសារ សូមអញ្ជើញបងប្អូនរួមអធិដ្ឋាន និងរិះគិតដូចតទៅ: យើងទាំងអស់គ្នាបានទទួលស្គាល់នូវធម៌មេត្តាករុណា និងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលស្រឡាញ់យើងយ៉ាងក្រៃលែង។ ប៉ុន្តែតាំងពីដើមរៀងមកមនុស្សតែងបដិសេធមិនទទួលនូវសេចក្ដីស្រឡាញ់ និងវត្តមានព្រះអង្គ។ រៀងរាល់ថ្ងៃ មានមនុស្សស្លាប់ដោយសង្គ្រាម ភេរវកម្ម និងភាពក្រីក្រ -ល-។ អ្នកមានអំណាចខ្លះរំលោភបំពានអ្នកក្រតូចតាច និងមានអំពើអសីលធម៌ជាច្រើនដូចជាក្មេងស្រីត្រូវគេរំលោភ និងត្រូវយកទៅលក់ដើម្បីបម្រើកាមគុណជាដើម។ អំពើហិង្សាកើតមានរាល់ថ្ងៃ ឥតឈប់ឈរ ដែលធ្វើឱ្យបុត្រធីតារបស់ព្រះអង្គកាន់តែឃ្លាតចាកឆ្ងាយពីព្រះអង្គ។

អតីតសម្ដេចប៉ាប យ៉ូហាន ប៉ូលទី២ បានចំណាយពេលវេលាយ៉ាងច្រើនក្នុងមុខងារលោកជាសម្ដេចប៉ាប ដើម្បីបង្រួបបង្រួមមនុស្សដោយសេចក្ដីស្រលាញ់ និងដោយសន្តិភាព។ អ្នកម្ដាយតេរេសា នៃក្រុងកាល់កុលថា ប្រទេសឥណ្ឌា សុខចិត្តបូជាកាយ-ចិត្ត ដើម្បីថែរក្សាអ្នកជំងឺ ដែលគេបោះបង់ចោល និងគ្មានតម្លៃ និងមានមនុស្សជាច្រើនទៀតដែលយកចិត្តទុកដាក់ចំពោះអ្នកក្រីក្រ ក្មេងកំព្រា ក្មេងអនាថា អ្នកជំងឺ អ្នករងគ្រោះថ្នាក់ធម្មជាតិជាដើម។ អ្នកនាំសារ សូមរំលឹកដល់បងប្អូនថា: តើបងប្អូនធ្លាប់យកចិត្តទុកដាក់ជាមួយក្មេងកំព្រាអនាថា អ្នកជំងឺ និងចេះជួយអ្នកក្រីក្រដែរឬទេ ? តើបងប្អូនបានសម្រុះសម្រួលជាមួយគ្នាហើយឬនៅ ? តើបងប្អូនបើកចិត្តចំពោះអ្នកដែលមករកខ្លួនបានកម្រិតណា ?

រីករាយបុណ្យចម្លង !

## ពិធីបាចទឹកព្រះពរ


Photo: Savên

មនុស្សទាំងចាស់ក្មេង ប្រុសស្រី គ្រីស្តបរិស័ទ និងពុទ្ធបរិស័ទ បានមកអង្គុយជុំគ្នាក្នុងព្រះវិហារដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងពិធី "បាចទឹកព្រះពរ"។ លោកបូជាចារ្យពេជ្រ អ្នកដឹកនាំកម្មវិធី មានប្រសាសន៍ថា: "កម្មវិធីនេះគឺជាលើកទី៤ ដែលគ្រីស្តបរិស័ទនៃព្រះសហគមន៍ចំណោមភូមិភាគបាត់ដំបង រៀបចំឡើងដើម្បីឱ្យគ្រីស្តបរិស័ទ និងពុទ្ធបរិស័ទស្គាល់គ្នាដើម្បីអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រទានភោគផលដល់អ្នកភូមិក្នុងពេលមួយឆ្នាំកន្លងមក និងធ្វើការបង្រួបបង្រួមរវាងគ្រីស្តបរិស័ទ និងពុទ្ធបរិស័ទ"។ អ្នកនាង ស៊ីថង ជាពុទ្ធបរិស័ទ ប្រាប់ថា សាសនាកាតូលិកមិនមានការប្រកាន់វណ្ណៈ ឬសាសនាឡើយ"។ កញ្ញា

## ធម្មយាត្រាដើម្បីសន្តិភាព


Photo: DR

កាលពីថ្ងៃទី៣ មីនា នៅព្រះសហគមន៍បាត់ដំបង មានទទួលស្វាគមន៍ ក្បួនធម្មយាត្រា លើកទី១៦ ដើម្បីសន្តិភាព សាមគ្គីភាព និងអហិង្សា ដែលបានដង្ហែចេញពីវត្តពោធិវាលខេត្តបាត់ដំបង ឆ្ពោះទៅកាន់ខេត្តបន្ទាយមានជ័យ។ ការដង្ហែនេះក្នុងគោលបំណងពង្រឹងនូវសាមគ្គីភាព សន្តិភាព និងការថែរក្សាបរិស្ថានធម្មជាតិ ជាពិសេសចង់ទូន្មានដល់យុវជន ឱ្យយល់ដឹងអំពីសីលប្រាំដើម្បីជៀសវាងការលង់ក្នុងអំពើអបាយមុខ សេពគ្រឿងញៀន និងជំងឺអេដស៍ជាដើម។ នេះជាលើកទី១ហើយ ដែលព្រះសហគមន៍ បានបង្កើននូវទំនាក់ទំនងរវាងសាសនាកាតូលិក និងពុទ្ធសាសនា ដោយការស្វាគមន៍ធម្មយាត្រា។ ក្នុងខណៈនោះដែរ លោកអភិបាល លោកបូជាចារ្យ គណៈកម្មការ និងគ្រីស្តបរិសទ័ជាច្រើននាក់ទៀត បានចូលរួមសម្តែងនូវសេចក្តីរីករាយជាទីបំផុត ដោយសារសាសនាយើងទាំងពីរមានទំនាក់ទំនងល្អជាមួយគ្នា។ ភិរុណ

## អេម៉ាន្វអែល សម្លេងពីព្រះសហគមន៍កាតូលិក

បាត់ដំបង: FM 91.0 Mhz
ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍។

ភ្នំពេញ: FM 99.5 Mhz
ម៉ោង ៧:០០-៧:៣០ រាល់ល្ងាចថ្ងៃសៅរ៍។

## បុណ្យដឹងគុណ ឬកតញ្ញូតាធម៌

កាលពីព្រឹកថ្ងៃទី០៧ មីនា ២០០៦ នៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូនារីទួលគោក សិស្សឆ្នាំទី១ និងឆ្នាំទី២ នៃជំនាន់ទី១២ និងទី១៣ បានរៀបចំនូវកម្មវិធីបុណ្យដឹងគុណ ឬបុណ្យកតញ្ញូតាធម៌ដល់បងស្រីសាលេស៊ាន។ យុវតីឈុន សុគន្ធារី ជាសិស្សផ្នែកលេខាធិការ បានចាប់អារម្មណ៍ថា: "ខ្ញុំរីករាយខ្លាំងណាស់ ខ្ញុំនឹងបន្តការដឹងគុណនេះទៀតសម្រាប់ម្តាយរបស់ខ្ញុំ"។ អ្នកគ្រូកុំព្យូទ័រ និងវប្បធម៌ខ្មែរ ហែម ពិសី ជាអតីតនិស្សិត នៅទីនោះបានប្រាប់បន្តថា: "បុណ្យនេះធ្វើឡើងដើម្បីបង្ហាញពីសេចក្តីស្រឡាញ់ មិនចំពោះតែអ្នកមានគុណឡើយ គឺសម្រាប់មិត្តភក្តិទាំងអស់ផងដែរ"។ បងស្រីតេរេសា ម៉ារីយ៉ា ជាជនជាតិវៀតណាម បានពោលថា: "បុណ្យនេះ ជាប្រពៃណីរបស់ក្រុមគ្រួសារបងស្រីបងប្រុសដុនបូស្កូទាំងអស់ ដើម្បីធ្វើឱ្យយុវជនចាប់អារម្មណ៍ដល់អ្នកមានគុណរបស់ខ្លួន"។ ក្នុងឱកាសដ៏សែនរីករាយនោះដែរ ក្រុមសិស្សក៏បានរួមគ្នាទិញជំនូនមួយជូនដល់សាលារបស់ខ្លួនផងដែរ។ នោះគឺបង់សម្រាប់អង្គុយលេងមួយ។ ធារី

## ព្រះជាអម្ចាស់ ទ្រង់ត្រាស់ហៅ


Photo: DR

"ខ្ញុំរីករាយណាស់ដែលព្រះជាអម្ចាស់បានត្រាស់ហៅខ្ញុំឱ្យក្លាយជាបុត្រធីតាទ្រង់។ ខ្ញុំសូមអរគុណលោកគ្រូ-អ្នកគ្រូ និងលោកបូជាចារ្យដែលបានបង្ហាត់បង្រៀន និងលើកទឹកចិត្តខ្ញុំឱ្យស្គាល់ព្រះយេស៊ូ"។ នេះគឺជាសំដីរបស់កញ្ញា មុំ ដែលបានទទួលជំហានទី២ រៀបចំឡើងនៅព្រះសហគមន៍ភូមិភាគបាត់ដំបងកាលពីថ្ងៃទី៥ មីនា ឆ្នាំ២០០៦ ដែលធ្វើឱ្យបងប្អូនគ្រីស្តបរិស័ទចូលរួមនៅក្នុងឱកាសនោះមានសេចក្តីអំណរសប្បាយរីករាយគ្រប់ៗគ្នា។ សូមបញ្ជាក់ថា អ្នកដែលទទួលជំហានទី២ មាននៅភ្នំពេញ ២០នាក់។ នៅកំពង់ចាម មាន ៣៣នាក់ និងនៅបាត់ដំបង មាន៥៤នាក់។ សុជាតិ



## ចេញលក់ហើយ!

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិកកំពុងចេញផ្សាយ CD ចម្រៀងវ៉ុលថ្មី គឺវ៉ុល ទី២ ដែលហៅថា "អេម៉ាន្វអែល" ដែលមានបទចម្រៀងលើកតម្កើងព្រះជាម្ចាស់ និងចម្រៀងសម្រាប់យុវជនកាតូលិកផងដែរ។ CD នេះ មួយវ៉ុល គឺមាន១២បទ តម្លៃ ២$។ ដូច្នេះបើសិនបងប្អូនគ្រីស្តបរិស័ទ ឬប្រិយមិត្តអ្នកអានមានចំណាប់អារម្មណ៍ចង់ជាវនូវ CD នេះ សូមអញ្ជើញទាក់ទងមកកាន់ការិយាល័យយើងខ្ញុំតាមរយៈលេខទូរស័ព្ទ: ០២៣ ២២៤ ១២០ ឬ ០១២ ២៤៤ ៧៧៨។

សូមអរគុណ!

## សិក្ខាសាលាគ្រូអប់រំជំនឿ

ពីថ្ងៃទី២៧ កុម្ភៈ ដល់ទី២៣ មីនា ២០០៦ នៅព្រះសហគមន៍បាត់ដំបង តាហែន ចំណោម និងតាពូង មានរៀបចំនូវអង្គសិក្ខាសាលាមួយ ដែលផ្តើមគំនិត ដោយលោកបូជាចារ្យសុផល។ សមាជិកចូលរួម គឺប្រមាណជា ៥៥នាក់។ ប្រធានបទក្នុងសិក្ខាសាលានេះ គឺពង្រឹងនូវគរុកោសល្យនៃគ្រូអប់រំជំនឿ។ លោកគ្រូខួង សារង់ ជាគ្រូអប់រំជំនឿ និងជាអ្នកដឹកនាំ នៅក្នុងសិក្ខាសាលានេះ បានមានប្រសាសន៍ថា: "សិក្ខាសាលានេះធ្វើឡើង គឺក្នុងគោលបំណងដើម្បីពង្រឹងផ្នែកគរុកោសល្យដល់គ្រូអប់រំជំនឿឱ្យកាន់តែប្រសើរឡើង"។

សុជាតិ

## រម្លឹកខួបសន្តឺល្វីស ម៉ារីលាក់

ថ្ងៃទី១៥ មីនា ២០០៦ ព្រះសហគមន៍បាត់ដំបងក្នុងមណ្ឌលសន្តវ៉ាំង សង់ដឺប៉ូល មានធ្វើពិធីរម្លឹកខួបលើកទី៥ នៃសន្តីល្វីស ម៉ារីលាក់ ជាសន្តីមួយរូបដែលបានបង្កើតក្រុមបុត្រីនៃមេត្តាករុណាជាមួយសន្តវ៉ាំងសង់ ដឺប៉ូល ដែលបម្រើប្រជាជនក្រីក្រ ជនពិការ ក្មេងកំព្រា អ្នកជំងឺ និងចាស់ជរា។ ក្នុងពិធីរម្លឹកខួបនេះ មានការចូលរួមពីក្មេងៗ មកពីមណ្ឌលសន្តវ៉ាំងសង់ ដឺប៉ូល ព្រះសហគមន៍តាពូង តាហែន និងបាត់ដំបងប្រមាណជាង ៣៥០នាក់។ ពិធីរម្លឹកខួបនេះ ធ្វើឡើង១ឆ្នាំម្តង ក្នុងគោលបំណងដើម្បីឱ្យគ្រីស្តបរិស័ទ និងអ្នកឯទៀតដឹងថា គាត់ជានរណា។ សុជាតិ




Photo: Fr. Evan
ការពូនភ្នំខ្សាច់តាមរបៀបព្រះសហគមន៍ពេលចូលឆ្នាំខ្មែរ

## ព្រះសហគមន៍គាំទ្រប្រពៃណីខ្មែរ

សង្ក្រានឆ្នាំថ្មី ឆ្នាំច នឹងចូលមកដល់ នាថ្ងៃសុក្រ ១រោច ខែចេត្រ ត្រូវនឹងថ្ងៃទី១៤ មេសា ឆ្នាំ២០០៦ វេលាម៉ោង៦ និង៤៨នាទីព្រឹក។ នៅព្រះសហគមន៍ ទូទាំងប្រទេសកម្ពុជាទាំងមូល ក៏មានរៀបចំប្រារព្ធធ្វើនូវពិធីបុណ្យចូលឆ្នាំនេះផងដែរ។ លោកបូជាចារ្យសេរ៉ាលដ៏ អ្នកណែនាំក្នុងព្រះសហគមន៍កំពង់ចាម បានមានប្រសាសន៍ទាក់ទងនឹងពិធីចូលឆ្នាំនេះថា: "ខ្ញុំក៏ដូចជា ព្រះសហគមន៍ចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះពិធីបុណ្យចូលឆ្នាំខ្មែរ។ នេះជាឱកាសមួយដើម្បីលើកតម្កើងសិរីរុងរឿងព្រះជាម្ចាស់ ដែលនាំ និងផ្តល់សុភមង្គលដល់យើង"។ លោកបូជាចារ្យបន្តថា ពិធីនេះមានអត្ថន័យធំធេងណាស់ទាំងពុទ្ធបរិស័ទ និងគ្រីស្តបរិស័ទ។ សម្រាប់គ្រីស្តបរិស័ទ គឺចង់អរព្រះគុណព្រះជាម្ចាស់ចំពោះអ្វីៗ ដែលកន្លងផុតទៅ អរគុណព្រះជាម្ចាស់ ដែលចាត់ទេវទូតឱ្យចូលរួមក្នុងជីវិតយើងគ្រប់កាលៈទេសៈដើម្បីបំពេញតម្រូវការ និងនាំទៅរកសុភមង្គល។ ពុទ្ធបរិស័ទធ្វើភ្នំខ្សាច់ដោយចង់រំលឹកគុណដល់ព្រះពុទ្ធដែលតែងនាំសិរីសួស្តីដល់ភូមិរបស់គេ។ សម្រាប់យើងមានភ្នំមួយ ដែលសំខាន់ ជាភ្នំនាំបុណ្យគុណដល់យើង គឺភ្នំលលាដ៏ក្បាលដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ យើងធ្វើភ្នំខ្សាច់ដោយមានឈើឆ្កាង៣ មានរូងភ្នំមួយបើកចំហ បញ្ជាក់ថា ព្រះយេស៊ូពុំនៅក្នុងនោះទេ ដែលនៅក្បែរភ្នំខ្សាច់ មានទៀនព្រះជ័យដើម្បីរំលឹកថាព្រះយេស៊ូ មានព្រះជន្មគង់នៅ ព្រះអង្គងើបឡើងពីចំណោមមនុស្សស្លាប់។ នៅថ្ងៃបញ្ចប់ ពុទ្ធបរិស័ទយករូបបដិមាករព្រះពុទ្ធមកស្រង់តាមផ្ទះ និងស្រង់ឱ្យឪពុកម្តាយ យាយតាចាស់ៗដែរ ដែលពិធីនេះរំលឹកយើងពេលព្រះយេស៊ូលាងជើងឱ្យក្រុមសាវ័កទាំងឡាយផងដែរ។ រាល់ដង យើងយករូបឈើឆ្កាងរបស់ព្រះយេស៊ូមកលាង រួចយើងយកទឹកព្រះពរទៅផ្ទះ។ រ៉ូ បូរ៉ា



លោកអភិបាលពេណ្ណាស៊ីអូ បាចទឹកព្រះពរ

# អគារសិក្សាថ្មី ចំណង ដែលយុវសិស្សក្រីក្រ

**អគារសិក្សាថ្មីមួយខ្នង កម្ពស់២ជាន់ មាន១០បន្ទប់ ត្រូវបានសង់បន្ថែមនៅលើទីទួលកណ្ដាលវាលស្រែក្នុងបរិវេណទីធ្លាវិទ្យាល័យចំណេះទូទៅ និងវិជ្ជាជីវៈសន្តប្រ៉ង់ស៊័រ ដែលហ៊ុមព័ទ្ធទៅដោយផ្ទះរបស់ប្រជាជន ក្នុងភូមិចំការទៀង ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ ដែលបានបើកសម្ពោធឱ្យប្រើប្រាស់កាលពីថ្ងៃទី២៦ កុម្ភៈ ២០០៦។**

សាលាសន្តប្រ៉ង់ស៊័រនេះ ជាវិទ្យាល័យព្រះសហគមន៍កាតូលិកតែមួយគត់ នៅក្នុងប្រទេសកម្ពុជា បានសាងឡើង នៅឆ្នាំ២០០៣ ក្នុងគោលបំណង ដើម្បីផ្ដល់ឱកាសឱ្យយុវសិស្សក្រីក្រ អាចបន្តការសិក្សានូវមុខជំនាញ ដែលខ្លួនពេញចិត្ត ដោយមិនចាំបាច់បន្តទៅសិក្សានៅទីក្រុងភ្នំពេញឡើយ។

នៅក្នុងពិធីសម្ពោធ អគារសិក្សាថ្មីនេះ នៃវិទ្យាល័យនេះ មានការចូលរួមជាអធិបតីភាពពីលោកអគ្គអភិបាលសាលវ៉ាទ័រ ពេណ្ណាស៊ីអូ អគ្គរាជទូតព្រះអាសនៈសម្ដេចប៉ាបបេណេឌីកតូទី១៦ ប្រចាំនៅកម្ពុជា លោកអភិបាលអេមីល ដេតម្ប ឯកឧត្តមសូ ឃុន ជារដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឯកឧត្តមអ្នកឧកញ៉ាចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយនិងមានការចូលរួមពីសំណាក់ឯកឧត្តមអភិបាលខេត្ត ប្រជាពលរដ្ឋព្រមទាំងសិស្សានុសិស្សនៅក្នុងតំបន់នេះយ៉ាងច្រើនកុះករផងដែរ។

នាឱកាសដ៏ឱឡារិកនោះ លោកបូជាចារ្យអូលីវិយេ ជាគណៈគ្រប់គ្រងសាលា ក៏បានពន្យល់ថា ៖ "មូលហេតុនៃការកសាងអគារនេះ គឺដោយសារតែចំនួនសិស្សនៅក្នុងសាលា មានចំនួនកើនឡើង និងបន្ទប់ក្នុងអគារសិក្សាចាស់ដែលមិនគ្រប់គ្រាន់សម្រាប់សិស្ស"។ លោកបន្តថា កម្មវិធីសិក្សានៅក្នុងសាលាមានដូចជាជំនាញលេខាធិការ កសិកម្ម ចិញ្ចឹមសត្វ របាំ តម្បាញ និងរៀនភ្លេង ជាពិសេសមានការបង្រៀននូវភាសាបរទេសផ្សេងៗ ដូចជាភាសាបារាំង និងភាសាអង់គ្លេស-ល-។

លោកអគ្គអភិបាលសាលវ៉ាទ័រ ពេណ្ណាស៊ីអូ មានប្រសាសន៍នៅក្នុងអង្គពិធីថា ៖ "ឥឡូវនេះ កន្លែងដែលមានភាពក្រីក្រ ព្រះសហគមន៍កាតូលិកត្រូវបញ្ចេញសកម្មភាពរបស់ខ្លួន ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស"។ លោកបានសង្កត់ធ្ងន់ថា ចំនុចផ្ដើមនៃការអភិវឌ្ឍន៍ធនធានមនុស្ស និងប្រទេសជាតិ គឺការអប់រំបណ្ដុះបណ្ដាលក្មេងៗ និងយុវជន ឱ្យមានចំណេះដឹងពិតប្រាកដ និងមានសមត្ថភាពដោះស្រាយជីវភាពផ្ទាល់ខ្លួនបាន។

បិតក្នុងឯកសណ្ឋានជាសិស្ស កញ្ញាកែម លក្ខិណា បាននិយាយថា ៖ "ខ្ញុំសម្រេចចិត្តរើសយក ជំនាញលេខាធិការ ព្រោះខ្ញុំនឹងចេះប្រើកុំព្យូទ័រ និងចេះភាសាអង់គ្លេស ដែលឱ្យខ្ញុំស្រួលរកការងារធ្វើ"។ ដោយឡែកយុវសិស្សយុន សារិន ដែលរៀនផ្នែកកសិកម្មបានឱ្យដឹងថា ក្នុងប្រទេសកម្ពុជាយើង ពុំសូវមានអ្នកចេះពិតប្រាកដ ខាងផ្នែកកសិកម្មនេះទេ"។ នេះគឺជាមូលហេតុដែលធ្វើឱ្យយុវសិស្សរូបនេះសម្រេចចិត្តរៀនវិជ្ជាកសិកម្ម។ សារិន បន្តថា ទៅពេលអនាគត លោកនឹងទទួលបានជំនាញពិតប្រាកដមួយ។ លោកនឹងចែករំលែកនូវចំណេះដឹងដល់បងប្អូនដើម្បីរួមគ្នាអភិវឌ្ឍភូមិកំណើត។

ទាក់ទងនឹងចំនុចនេះ លោកបូជាចារ្យ អូលីវិយេ បានឱ្យដឹងថា ៖ "ទាំងចំណេះដឹង ទាំងជំនាញនៅពុំទាន់អាចធ្វើឱ្យក្លាយទៅជាពលរដ្ឋដ៏ល្អទេ។ នៅពេលណា យើងបង្កើតជាសមាជិក ចេះទទួលខុសត្រូវ និងមានចិត្តស្មោះស្ម័គ្រ នៅពេលនោះ យើងមានកម្លាំងកាយ និងសមត្ថភាពដែលអាចកសាងសង្គមឱ្យមានសេរីភាព យុត្តិធម៌ ព្រមជាមួយនិងការគោរពដល់គ្នាទៅវិញទៅមកដើម្បីជួយអភិវឌ្ឍស្រុកកំណើតឱ្យរីកចម្រើន"។



ក្រុមគណៈប្រតិភូជាន់ខ្ពស់ចូលរួមកាត់ខ្សែបូសម្ពោធអគារសិក្សាថ្មី

Photos: L. Sovanna

នៅក្នុងពិធីដ៏ប្រសើរនេះដែរ ឯកឧត្តមអ្នកឧកញ៉ាចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានធ្វើការចាប់អារម្មណ៍ថា ៖ "ការដែលអាចអភិវឌ្ឍប្រទេសជាតិមួយទៅបាន គឺវាអាស្រ័យទៅលើធនធានមនុស្ស ធនធានធម្មជាតិ ស្ថិរភាពនយោបាយ និងសន្តិភាព។ ក្នុងចំណោមកត្តាទាំងនេះ ស្ថិរភាពនយោបាយ ហើយនិងធនធានមនុស្សគឺមានលក្ខណៈជាអាយុជីវិតទៅដល់ដំណើរការអភិវឌ្ឍន៍ប្រទេសជាតិ"។ ឯកឧត្តម ក៏បានកោតសរសើរសកម្មភាពរបស់ព្រះសហគមន៍ចំការទៀង ដែលបានប្រែក្លាយតំបន់ដែលធ្លាប់តែមានសភាពស្ងាត់ជ្រងំ ទៅជាតំបន់មួយ រស់រវើកមានមនុស្សចេះដឹងច្រើន ដែលជាការរួមចំណែកក្នុងគោលដៅរបស់រដ្ឋាភិបាល ក្នុងការបំបាត់ភាពក្រីក្រ និងអនក្ខរភាពនៅតំបន់ដាច់ស្រយាល។

អត្ថបទដោយលី សុវណ្ណា

## ស្ថិតិមណ្ឌលអប់រំ

យោងទៅតាមរបាយការណ៍របស់ក្រសួងអប់រំយុវជន និងកីឡា ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល មានវិទ្យាល័យសរុប ចំនួន២១២ និងសិស្សសរុបចំនួន៣៨៤៥១៩នាក់ ដែលសិស្សស្រីមានចំនួន៣៨៨៦៦នាក់ នៃឆ្នាំសិក្សា២០០៣-០៤។ ចំពោះវិទ្យាស្ថានជំនាញកសិកម្ម មាន៤ គឺរួមទាំងវិទ្យាល័យចំណេះទូទៅ និងវិជ្ជាជីវៈសន្តប្រ៉ង់ស៊័រ ដែលទើបនឹងកកើតឡើងនេះផងដែរ។



# មណ្ឌលអប់រំសុខភាពអ្នកជំងឺអេដស៍ត្រូវបានសម្ពោធ

**ថ្ងៃ២៧ កុម្ភៈ មណ្ឌលអប់រំសុខភាពមួយត្រូវសម្ពោធក្រោមអធិបតីភាពឯកអគ្គរាជទូតសាលវ៉ាទ័រ ពេណ្ណាស៊ីអូ លោកអភិបាលអេមីល និងឯកឧត្តមម៉ុត ម៉ន ជាអភិបាលរងក្រុងកែប។**



ថតរូបជុំគ្នាពេលសម្ពោធមណ្ឌលសុខភាពថ្មី

ផ្ទះចំនួន១០ខ្នងធ្វើពីស៊ីម៉ង់ស៍ ដំបូលប្រក់ស្បូវ ដែលមានប្រវែង ៣គុណនឹង៥ម៉ែត្រ សង់ដាច់ពីគ្នានេះ មានឈ្មោះថា ៖ "មណ្ឌលអប់រំថែទាំសុខភាពជីវិតសន្តយ៉ូហាន ប៉ូល ទី២"។

មណ្ឌលនេះហ៊ុមព័ទ្ធទៅដោយព្រៃ និងជ្រលងភ្នំដែលជាអតីតតំបន់តស៊ូរបស់ខ្មែរក្រហម ភ្នំវល្លិ ហើយសព្វថ្ងៃនេះ មានប្ដីប្រពន្ធកំពុងរស់នៅ ចំនួន ១៨នាក់ និងកូនចំនួន ២១នាក់។

ថ្លែងសុន្ទរកថាទៅកាន់ប្រជាជន ក្នុងពិធីនោះ លោកបូជាចារ្យអូលីវីយេ សមាជិកសាសនទូតក្រៅប្រទេស ក្រុងប៉ារីស ដែលជាអ្នកចាប់ផ្ដើមកសាងមណ្ឌលថ្មីនេះមានប្រសាសន៍ថា ៖ "ព្រះសហគមន៍កាតូលិក បានកសាងនូវអគារនេះ ពីព្រោះយើងចង់ជួយឱ្យ អ្នកផ្ទុកមេរោគអេដស៍ ឱ្យមានជីវិតមួយដ៏ល្អ និងមានសេចក្ដីសង្ឃឹមក្នុងជីវិតរបស់ពួកគេ នាថ្ងៃអនាគត"។ លោកបន្ដែរថា សម្ដេចប៉ាបយ៉ូហាន ប៉ូល ទី២ ក៏ធ្លាប់មានបន្ទូលថា ៖ "ជីវិតរបស់មនុស្សគឺមានតម្លៃ សូមឱ្យគោរពជីវិតមនុស្ស" ដូចនេះទើបយើង បានដាក់ឈ្មោះដល់មណ្ឌលនេះ ថា "មណ្ឌលអប់រំថែទាំសុខភាព ជីវិត យ៉ូហាន ប៉ូល ទី២"។ នៅក្នុងនោះ លោកបានអរគុណដល់លោកអគ្គរាជទូត លោកអភិបាលអេមីល ដេតម្ប និងអភិបាលរងក្រុងកែបដែលបានគាំទ្រនូវគម្រោងការ ដ៏តូចនេះ គឺដើម្បីជួយទៅដល់បងប្អូនអ្នកផ្ទុកមេរោគអេដស៍។

ក្នុងពិធីដ៏មានតម្លៃនេះ លោកឯកអគ្គរាជទូតនៃទីក្រុងរ៉ូម សាលវ៉ាទ័រ ពេណ្ណាស៊ីអូបានមានប្រសាសន៍ ទៅកាន់ប្រជាពលរដ្ឋ ដែលចូលរួមដែរថា ៖ "វាជាការត្រឹមត្រូវ ដែលមណ្ឌលនេះបានដាក់ឈ្មោះ បន្ទាប់ពីសម្ដេចប៉ាប យ៉ូហាន ប៉ូល ទី២ ដ៏មហិមា ជាអ្នកបម្រើ ព្រះជាម្ចាស់ ហើយលោកតែងបង្ហាញការយកចិត្តទុកដាក់យ៉ាងពិសេស ចំពោះអ្នកជំងឺ ដែលបានទទួលរងការឈឺចាប់ពីសង្គម។ លោកក៏រីករាយក្នុងការសួរសុខទុក្ខ និងដោះស្រាយបញ្ហាដល់ពួកគេ"។ លោកឯកអគ្គរាជទូតក៏បន្តថា មណ្ឌលនេះគឺជាទីសក្ការៈមួយ នៅក្នុងប្រទេសកម្ពុជា ដើម្បីជាការរម្លឹកទៅដល់សម្ដេចប៉ាបយ៉ូហាន ប៉ូល ទី២ ដែលលោកតែងតែយកចិត្តទុកដាក់ព្រួយបារម្ភ និងគិតពីប្រទេសនេះជានិច្ច។

ជាមួយនិងស្នាមញញឹមប្រកបដោយក្ដីសង្ឃឹម អ្នកស្រីង៉ែត វណ្ណៈ អាយុ៣៥ឆ្នាំ និងមានផ្ទុកមេរោគអេដស៍ តាំងពីឆ្នាំ១៩៩៤ បានបញ្ជាក់ឱ្យដឹងថា ៖ "ខ្ញុំពិតជាអរគុណដល់លោកឪពុកអូលីវីយេ ដែលបានជួយគ្រួសារខ្ញុំ។ កូនរបស់ខ្ញុំអាចទៅសាលាបាន ខ្ញុំសង្ឃឹមថា វានឹងមានអនាគតល្អ ដូច្នេះខ្ញុំពុំព្រួយបារម្ភ អំពីអនាគតរបស់ពួកគេនោះឡើយ"។ ចំណែក នាងធានសូធាន បានប្រាប់ឱ្យដឹងផងដែរថា ៖ "ខ្ញុំមានក្ដីសប្បាយរីករាយហើយពោរពេញទៅដោយក្ដីសង្ឃឹម ព្រោះមណ្ឌលនេះ គឺប្រៀបដូចជាអ្នកផ្ដល់កំណើត ទី២ ដល់រូបខ្ញុំ ព្រមទាំងអ្នកជំងឺដទៃផ្សេងទៀតផងដែរ"។

ពាក្យថា "ស្នេហា-អាពាហ៍ពិពាហ៍" មានអត្ថន័យធំធេងណាស់សម្រាប់មនុស្សគ្រប់រូប មិនថាក្មេង ចាស់ ប្រុស ឬស្រីឡើយ។ ចំណងស្នេហាប្រែក្លាយទៅជាចំណងអាពាហ៍-ពិពាហ៍ ដែលកម្រមាននរណាម្នាក់អាចជៀសផុតបាននៅក្នុងជីវិត។ សុភាសិតខ្មែរមួយបានពោលថា "កូលាបតែងមានបន្លា ស្នេហាតែងមានឧបសគ្គ"។ តើអ្នកចង់ឱ្យស្នេហាអ្នកក្លាយ ដូចសុភាសិតនេះឬទេ? ដូច្នេះយើងម្នាក់ៗ ត្រូវចេះគិតមើលថា តើត្រូវធ្វើយ៉ាងណាដើម្បីឱ្យសេចក្ដីស្នេហារបស់យើងឈានទៅដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍? តើយើងបានត្រៀមលក្ខណៈក្នុងការចាប់យកជីវិតអាពាហ៍ពិពាហ៍ហើយឬនៅ?

# យុវវ័យ និងការឈាន ដល់អាពាហ៍ពិពាហ៍



Photo: S. Philong

ស្នេហាដ៏មានសុភមង្គលគឺជាការប្រគល់មនោសញ្ចេតនាឱ្យគ្នាទៅវិញទៅមកដោយចិត្តភក្ដី ដែលរូបកាយពីរនាក់ហាក់ដូចតែមួយ



Photo: K. Kagha

បើសិនប្រិយមិត្តទាំងឡាយមានចំណាប់អារម្មណ៍ចង់ជជែកពិភាក្សាអំពីអត្ថបទនេះ សូមផ្ញើសំបុត្រមកកាន់ការិយាល័យព្រឹត្តិបត្រ "អ្នកនាំសារ" តាមរយៈលោកឪពុក បងប្រុស-បងស្រីដែលនៅជិតបំផុត។

## តើសេចក្ដីស្រលាញ់ និងការរៀបអាពាហ៍ពិពាហ៍មានអត្ថន័យយ៉ាងណា?

តាមការអធិប្បាយក្នុងសៀវភៅ ដែលមានចំណងជើងថា: "យើងជួបស្នេហ៍ស្មោះហើយ" ពន្យល់ថា : សេចក្ដីស្រឡាញ់មានន័យទូលំទូលាយ លើសពីទំនាក់ទំនងស្នេហា រវាងបុរស និងនារីទៅទៀត។ មនុស្សយើងមិនមែនរស់នៅឯកោ ម្នាក់ឯងទេ។ គឺយើងរស់នៅដោយសារគេ និងដើម្បីគេ។ សេចក្ដីស្រលាញ់គឺជាគ្រឹះនៃសុភមង្គលក្នុងរង្វង់គ្រួសារ។ អ្នកដែលស្រលាញ់ តែងសម្ដែងចេញឱ្យឃើញ តាមរបៀបផ្សេងៗ ជាច្រើនឥតគណនា។ ហេតុនេះហើយ ការឱ្យអត្ថន័យលើពាក្យថា : "សេចក្ដីស្រលាញ់" វាគឺមានការពិបាក។

ក្នុងឱកាសនេះ លោកបូជាចារ្យសេរ៉ាលដ៏ នៃព្រះសហគមន៍កំពង់ចាម បានផ្ដល់អត្ថន័យពាក្យ "អាពាហ៍ពិពាហ៍" ដោយផ្ដោតលើន័យសំខាន់ ៣យ៉ាង។ ចំពោះយុវជន កាលណា ២ នាក់រៀបការ គឺគេបង្ហាញមុខក្នុងសង្គម និងចំពោះបងប្អូន។ សង្គមផ្ដល់មុខងារមួយធំដល់ពួកគេ ឱ្យក្លាយជាប្ដីប្រពន្ធ និងជាឪពុកម្ដាយ គឺមានន័យថា សង្គមផ្ដល់សិទ្ធិ និងតួនាទីដើម្បីបន្តជីវិត។ ចំពោះសង្គម ជារបៀបចងទំនាក់ទំនង ឬសម្ព័ន្ធមេត្រីក្នុងសង្គម ដែលមានគ្រួសារ២ ជួបគ្នា ផ្សារភ្ជាប់គ្នាជាសង្គមគ្រួសារតែមួយ។ សម្រាប់អត្ថន័យជំនឿ គឺក្នុងនាមជាគ្រិស្តបរិស័ទ បើមនុស្ស២នាក់ ពិតជាស្រឡាញ់គ្នា វាត្រលប់ទៅជាសញ្ញានៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ឬជាធម៌មេត្តាករុណាពីព្រះអង្គដល់មនុស្សដទៃៗទៀត។ នេះប្រៀបដូចជា ព្រះសហគមន៍ និងព្រះគ្រិស្តជាស្វាមីភរិយា មានន័យថា ព្រះគ្រិស្តជាស្វាមី និងព្រះសហគមន៍ជាភរិយា។

## ស្នេហាមានជំហានដូចម្ដេច?

ដំណើរនៃសេចក្ដីស្នេហា គឺបុរស ឬស្ត្រីតែងស្រមៃរកមនុស្សមានលក្ខណៈដែលខ្លួនចូលចិត្ត។ ថ្ងៃណាមួយ គេនឹងជួបអ្នកដែលមានលក្ខណៈស្រដៀងនឹងការស្រមៃ។ ពេលនោះ គេពេញចិត្ត មានទំនាក់ទំនងគ្នា និងក៏ក្លាយជាស្នេហា។ នៅក្នុងដំណាក់កាលនេះ ជាទូទៅ មនុស្សមើលឃើញតែលើចំនុចល្អឥតខ្ចោះនៃដៃគូ។ ដៃគូខ្លះ ដល់ដំណាក់កាលនេះ ក៏សម្រេចចិត្តរៀបការភ្លាម តែគេមិនដឹងថា អ្វីខ្លះទៀត អាចនឹងកើតឡើងទេ។ ឆ្លងកាត់ទំនាក់ទំនងគ្នាមួយរយៈមក អ្នកទាំង២ ក៏ចាប់ផ្ដើមមើលឃើញពីចំនុចមិនល្អ របស់ដៃគូរៀងៗខ្លួន។ ពេលនោះ ពួកគេនឹងមានការធ្លាក់ទឹកចិត្តរវាងគ្នា។



ផ្អែកលើចំនុចនេះ លោកប៉ាង រតនា មន្ត្រីសម្របសម្រួលនៃកម្មវិធីការ៉ូល និងសេដ្ឋា និងមានបទពិសោធន៍ច្រើនជាមួយយុវវ័យ បានបកស្រាយពីដំណើរការនៃសេចក្ដីស្នេហា របស់ពួកគេថា នៅពេលមានការធ្លាក់ទឹកចិត្តចំពោះគ្នា ពេលនោះមានលទ្ធភាព៣ ដែលអាចកើតឡើង ក្នុងទំនាក់ទំនងរបស់ពួកគេ។ លទ្ធភាពទី១ ដៃគូទាំង២ មិនដឹងត្រូវធ្វើយ៉ាងណា ហើយពុំដែលសម្រេចធ្វើអ្វីទាំងអស់ ពួកគេមិនដឹងថា តើគួរផ្ដាច់ ឬក៏បន្តទំនាក់ទំនងនេះទៀត។ លទ្ធភាពទី២ បើដៃគូទាំង២ គិត និងពិភាក្សាគ្នា ឃើញថា ចំនុចមិនល្អរបស់ដៃគូខ្លួនជាបញ្ហាធំសម្រាប់ខ្លួន ពេលនោះ ការផ្ដាច់ទំនាក់ទំនងគ្នា វាជាមធ្យោបាយមួយប្រសើរបំផុត។ រីឯលទ្ធភាពទី៣ នោះ បើដៃគូទាំង២ គិត និងធ្វើការពិភាក្សាគ្នាឃើញថា ចំនុចមិនល្អរបស់ដៃគូខ្លួន គឺម្នាក់ៗ អាចទទួលយកបាន ហើយក៏យល់ព្រមគ្នា នៅចំនុចសំខាន់ៗ ផ្សេងទៀតជាមួយគ្នា ពេលនោះ ពួកគេទាំង២ អាចបន្តទំនាក់ទំនងតទៅទៀត ហើយពួកគេអាចរៀបការ និងអាចរស់នៅជាមួយគ្នាបាន។

ស្នេហាមានដំណើរការរបស់វា ដោយខ្លះឈានដល់ ការរៀបការ។ អ្នកខ្លះទើបតែឈានដល់ដំណាក់កាល មើលឃើញតែភាពល្អឥតខ្ចោះ ក៏សម្រេចចិត្តរៀបការ ក្រោយមកមានការធ្លាក់ទឹកចិត្ត ពេលនោះគ្រួសារអាចមានបញ្ហានឹងគ្នា។

លោកស្រីម៉ារីយ៉ាម អ្នកទទួលខុសត្រូវលើកម្មវិធីនៃអង្គការការ៉ូល និងសេដ្ឋាមានប្រសាសន៍ថា: "ស្នេហាដែលមានភាពចាស់ទុំ គឺការចេះគ្រប់គ្រងលើភាពខុសគ្នា និងត្រូវចេះយល់ព្រមពីចំនុចសំខាន់ៗរបស់ដៃគូដែរ ព្រោះបើយើងមានភាពខុសគ្នាពេក ការរស់នៅជាមួយគ្នា គឺមិនបានយូរទេ។ ដូច្នេះស្នេហាពុំមែនមានត្រឹមតែមនោសញ្ចេតនាទេ គឺស្នេហាត្រូវគិតពិចារណាច្រើនពីរឿងទាំងអស់ខាងលើដែរ"។

## អាពាហ៍ពិពាហ៍ជាហេតុនាំឱ្យបាត់សេរីភាពឬ?

នៅពេលនរណាម្នាក់ពុំទាន់រៀបការ គឺគេមានសេរីភាព និងការទទួលខុសត្រូវផ្សេងសម្រាប់ខ្លួនឯង ប៉ុន្តែ នៅពេលដែលគេមានដៃគូ តើគេត្រូវប្រើសេរីភាព និងការទទួលខុសត្រូវរបស់គេជាមួយដៃគូយ៉ាងណា? តើត្រូវប្រើសេរីភាពនឹងដៃគូដើម្បីភាពសុខសាន្ត ឬប្រើនូវសេរីភាព ក្នុងន័យ ផ្លូវអ្វីមួយផ្សេងទៀត? ក្នុងន័យនេះដែរ អ្នកស្រីលី សុម៉ាណា ជាមន្ត្រីសម្របសម្រួលនៃកម្មវិធីការ៉ូល និងសេដ្ឋា ក៏បានចូលរួមឱ្យដឹងថា មានចំនុចជាច្រើនដែលត្រូវធ្វើ ដើម្បីឱ្យក្លាយជាដៃគូដ៏ល្អនឹងគ្នា ប៉ុន្តែពេលដែលយើងធ្វើ ដើម្បីឱ្យក្លាយជាគូស្វាមីភរិយាល្អនោះ យើងគិតថា យើងបាត់បង់នូវសេរីភាព តាមពិត ចំនុចនេះ វាមិនមែនទេ គ្រាន់តែជួនកាលអ្នកខ្លះគិតថា ពីមុនគេធ្លាប់រស់នៅតែម្នាក់ឯងធ្វើអ្វីក៏បាន ប៉ុន្តែនៅក្រោយពេលរៀបការរួច គាត់នៅធ្វើដូច្នេះទៀត តើស្វាមី ឬភរិយាអាចរស់នៅជាមួយគ្នាទៀតបានឬទេ? ឧ្យាង បុស ពេលដែលគាត់រៀបការហើយ តម្រូវឱ្យគាត់ធ្វើការកាត់បន្ថយនូវសេរីភាពគាត់ ដូចជា ការដើរលេងក្រៅជាមួយមិត្តភ័ក្តិរបស់គាត់ជាដើម។ ដូច្នេះដើម្បីឱ្យក្រុមគ្រួសារយើងល្អ យើងត្រូវកែប្រែនូវទម្លាប់ខ្លះៗ ដែលធ្លាប់ធ្វើពីមុន។ ម្យ៉ាងទៀត ការកាត់បន្ថយសេរីភាពខ្លះនេះ មិនមែនធ្វើឱ្យយើងឈឺចាប់ពេកទេ ព្រោះយើងបានបំពេញមកវិញជាមួយដៃគូ។

លោកសម្បត្តិ ជានិស្សិតមួយរូប នៅសកលវិទ្យាល័យន័រតុន យល់ថា អាពាហ៍ពិពាហ៍ គឺគ្រាន់តែជាពាក្យមួយ ដែលគេថាអ្នកទាំង២ រស់នៅជាមួយគ្នា ប៉ុន្តែពុំអាចចងគ្នាបានឡើយ។ អាពាហ៍ពិពាហ៍មិនមែនជាចំណងទេ ពុំមែនទាំង២នាក់ គ្មានសេរីភាពទេ វាគ្រាន់តែជាប្រពៃណីមួយសម្រាប់ឱ្យគេដឹងថាអ្នកទាំង២ នៅជាមួយគ្នា បានរៀបការជាមួយគ្នា បើសិនជាចំណងនោះ មិនមែនមានអ្នកខ្លះលែងលះគ្នាទេ។

លោកប៉ាង រតនា បានបន្តលើចំនុចនេះថា ចំពោះសេរីភាព...

**ការ៉ូល និង សេដ្ឋា**
គឺជាឈ្មោះអង្គការដែលបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាទៅលើទំនាក់ទំនងរវាងបុរស និងស្ត្រីដោយផ្ដោតទៅលើចិត្តកាយ និងប្រាជ្ញារបស់ពួកគេ។ ប្រសិនបើមិត្តយុវវ័យ ឬអ្នកអានចង់ស្វែងយល់អំពីការស្វែងរកដៃគូ និងទាក់ទងនឹងបញ្ហាស្នេហាយុវវ័យ។ សូមទំនាក់ទំនងនៅកាន់អង្គការនេះ តាមរយៈទូរស័ព្ទលេខ : ០២៣ ៩៩៤ ៤៣៤។

នេះក៏ទាក់ទងនឹងកាយ ចិត្ត (អារម្មណ៍) និងគំនិតប្រាជ្ញាមាន ន័យថា មនុស្សទាំងប្រុស ស្រី និងគ្រប់ជាតិសាសន៍ មានរូបកាយ ចិត្ត (អារម្មណ៍) និងគំនិតប្រាជ្ញាដូចៗគ្នា។ ដូចនេះបើយើងដឹងថា ដៃគូយើងមាននូវរូបកាយ ចិត្ត (អារម្មណ៍) និងគំនិតប្រាជ្ញា យើងក៏មានដែរ ហើយបើសិនជាយើងធ្វើឱ្យប៉ះពាល់ដល់ផ្នែកណា១ វាក៏នឹងធ្វើឱ្យប៉ះពាល់ដល់ផ្នែក២ផ្សេងទៀត។ តួយ៉ាងបើសិនដៃគូប្រើសេរីភាពខ្លួនជ្រុលពេក គឺធ្វើឱ្យប៉ះពាល់ដល់ចិត្ត (អារម្មណ៍) របស់ដៃគូខ្លួន ពេលនោះធ្វើឱ្យដៃគូឈឺចាប់ខ្លាំង ដែលអាចឱ្យរូបកាយរបស់គាត់ធ្លាក់ខ្លួនមានជំងឺ ហើយគំនិតប្រាជ្ញារបស់គាត់ អាចនឹងគិតអ្វី ប្លែកៗ ដូចជាខឹងមួម៉ៅ និងអាចទៅជាសងសឹកជាដើម។

ទាក់ទងទៅនឹងចំនុចនេះ អ្នកនាងរ័ត្ន បូផា ទើបតែរៀបការរួច ក៏បានប្រាប់ឱ្យដឹងថា ក្រោយពេលនាងរៀបការ និងមុនរៀបការ មានលក្ខណៈខុសគ្នា ដំបូងការដើរហើរ តែ២នាក់ធ្វើឱ្យ វាមិនសមនឹងភ្នែកញាតិ តែនាងមានសេរីភាពច្រើន។ ក្រោយរៀបការ សេរីភាពរបស់នាងមានការថមថយបន្តិចដោយសារនាងមិននៅម្នាក់ឯងដូចមុន។ នាងបន្តថា អ្វីដែលធ្វើឱ្យគូស្វាមីនាង មានសុភមង្គលនោះ គឺមកពីការពេញចិត្តទាំងសងខាង និងមានការយល់ចិត្តគ្នាទៅវិញទៅមក។

### សេចក្តីស្រលាញ់ត្រូវការអ្វីខ្លះ ?

លោកប៉ាង រតនា ក៏បានពន្យល់ទៀតថា តម្រូវការនៃសេចក្តីស្រលាញ់ របស់បុរស និងស្ត្រីមាន៥ ដូចជា ការទទួលស្គាល់គ្នា ការរួមរស់ជាមួយគ្នា ការថ្នាក់ថ្នម សមិទ្ធផល និងការរួមភេទ-ល-។ តម្រូវការ ទាំង៥នេះ គឺតម្រូវឱ្យមានទាំងសងខាង។ ហើយម្យ៉ាងទៀត គ្រួសារនីមួយៗក៏តម្រូវឱ្យមាននូវការគ្រប់គ្រងតណ្ហា ការពិភាក្សាគ្នា ការស្ញៀកពាក់ ឱ្យបានសមរម្យ ការអត់អោនឱ្យគ្នា ការស្មោះត្រង់នឹងគ្នា ការយកចិត្តទុកដាក់គ្នាទៅវិញទៅមក និងការលើកលែងទោស។

លោកស្រីម៉ារីយ៉ាមឱ្យដឹងដែរថា សេចក្តីត្រូវការ ទាំង៥នេះ វាមានសារៈសំខាន់ណាស់ នៅក្នុងរឿងស្នេហា។ សេចក្តីត្រូវការរវាងប្តី និងប្រពន្ធ មានលក្ខណៈស្រដៀងគ្នា ហើយមានលក្ខណៈខុសគ្នា ដូចជាបុរសចង់មានកូន តែស្ត្រីមិនចង់មានឥឡូវ។ ដូច្នេះយើងត្រូវមានការយោគយល់គ្នា ចេះពិភាក្សាគ្នាទើបធ្វើឱ្យសេចក្តីស្នេហាយើងគង់វង្សយូរអង្វែង។

**សូមធ្វើការពិចារណា:**

បុរសត្រូវការភាពបរិសុទ្ធពីមនុស្សស្រី (ព្រហ្មចារី) ប៉ុន្តែតើបុរសមានទុកភាពបរិសុទ្ធរបស់ខ្លួនសម្រាប់ស្ត្រីជាភរិយារបស់ខ្លួនដែរឬទេ ? នារីដែលនៅរ៉ៃយក្រមុំ តែគ្មានភាពស្មោះត្រង់ និងស្ត្រីដែលអស់ភាពបរិសុទ្ធ តែមានភាពស្មោះត្រង់ចំពោះបុរសដែលជាស្វាមី តើបុរសជ្រើសរើសយកស្ត្រីរូបណាសម្រាប់ធ្វើជាគូអនាគតរបស់ខ្លួននោះ ?

## លោកបូជាចារ្យ ប្រ៊ុយណូ: សេចក្តីស្រឡាញ់ គឺថ្វាយខ្លួនសម្រាប់អ្នកដទៃ កុំគិតប្រយោជន៍ផ្ទាល់ខ្លួន


Photo: L. Sovanna

"ស្នេហា" គឺជារឿងមួយធម្មតា និងកើតឡើងនៅលើគ្រប់ជីវិតមនុស្សទាំងអស់គ្នា។ យើងត្រូវការស្រលាញ់នរណាម្នាក់រហូតដល់បានរៀបការជាមួយគ្នាក្លាយជាស្វាមី ឬភរិយា និងរួមរស់ជាមួយគ្នាអស់មួយជីវិត។ ពិតមែនតែស្នេហាជាចំនុចមួយធម្មតា ប៉ុន្តែវាគឺជាបញ្ហាមួយដែលមនុស្សគ្រប់រូបត្រូវតែធ្វើការពិចារណា និងយកចិត្តទុកដាក់ឱ្យបានម៉ត់ចត់ជាមួយបញ្ហានេះ ព្រោះវាទាក់ទងនឹងអាយុជីវិតរបស់មនុស្សពីរនាក់ដែលស្ម័គ្រចិត្តរស់នៅជាមួយគ្នាអស់មួយជីវិត។ ព្រះគម្ពីរចែងថា: "អត់មានរូបកាយពីរទេ គឺមានតែមួយ" ដូចជាពីរនាក់ដែលរួមបញ្ចូលគ្នាទៅជាមនុស្សម្នាក់ដោយសារតែការស្រលាញ់គ្នា មានន័យថាជីវិតរបស់គេទាំងពីរ ហាក់ដូចជាតែមួយ។ ពេលដែលម្នាក់មានការឈឺចាប់ ម្នាក់ទៀតក៏ឈឺចាប់ដែរ ឬនៅពេលដែលម្នាក់មានអំណរសប្បាយ ម្នាក់ទៀតក៏សប្បាយ។ នៅក្នុងជីវិតមនុស្សយើងម្នាក់ៗ ត្រូវការមានអ្នកស្រលាញ់ ត្រូវការទទួលសេចក្តីស្រលាញ់ពីគេ និងចង់បង្ហាញការស្រលាញ់របស់ខ្លួនចំពោះគេដែរ ដូចជាចំពោះឪពុកម្តាយ បងប្អូន មិត្តភ័ក្តិ និងជាពិសេសសម្រាប់មនុស្សម្នាក់ដែលយើងមានសេចក្តីស្រលាញ់ខ្លាំងនៅក្នុងជីវិតរបស់យើង។ ដូច្នេះសេចក្តីស្រលាញ់ គឺជាជីវិត ឬជាអ្វីមួយដែលនាំឱ្យយើងមានជីវិត។ ប្រសិនបើយើងមិនមានសេចក្តីស្រលាញ់ទេ នោះប្រាកដជាធ្វើឱ្យជីវិតយើងគ្មានក្តីសង្ឃឹម មានការពិបាកចិត្ត គ្មានកម្លាំងកំហែង ឬអាចបណ្តាលឱ្យយើងឈឺចាប់ខាងផ្លូវចិត្ត ឬផ្លូវកាយជាដើម។ ដូច្នេះសេចក្តីស្រលាញ់គឺប្រៀបដូចជាកម្លាំងមួយដ៏រឹងមាំសម្រាប់ដឹកនាំជីវិតរបស់មនុស្សយើងឱ្យឈានទៅកាន់ភាពជោគជ័យ។

សម្រាប់ព្រះយេស៊ូ នៅពេលដែលព្រះអង្គយាងមកនៅលើផែនដីនេះ អ្វីដែលព្រះអង្គទ្រង់បានមានព្រះបន្ទូលច្រើនជាងគេនោះ គឺសេចក្តីស្រលាញ់ ដោយសារនៅក្នុងពិភពលោកយើងនេះ មានបញ្ហាជាច្រើនដែលបញ្ហាទាំងនេះបណ្តាលមកពីការខ្វះការស្រលាញ់រវាងគ្នា និងគ្នា។ ព្រះយេស៊ូមានព្រះបន្ទូលថា: "សេចក្តីស្រលាញ់គឺការថ្វាយខ្លួនទាំងស្រុងសម្រាប់អ្នកដទៃដោយមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន"។ សេចក្តីស្រលាញ់គឺជាការស្វែងរកប្រយោជន៍សម្រាប់គេ មិនមែនរកប្រយោជន៍សម្រាប់យើង។

អត្ថបទដោយ មុំ គន្ធា





**"មណ្ឌលពន្លឺនៃមេត្តា" ទទួលក្មេងពិការរបស់អង្គការជេស៊ូត Jesuit Service បានផ្តល់អនាគតដល់ក្មេងពិការគរ-ថ្លង់ និងពិការជើងជាដើម។ ភាពអស់សង្ឃឹមនៃក្មេងៗពិការមួយផ្នែកនៅកម្ពុជាត្រូវបានបណ្តុះឡើងវិញដោយអង្គការមួយនេះ។**

# មណ្ឌលពន្លឺនៃមេត្តា ទទួលកុមារពិការ


Photo: H. Soktheary

កុមារៗពិការនៅបឹងទំពន់ថតរូបជាអនុស្សាវរីយ៍ក្នុងមណ្ឌលពន្លឺនៃមេត្តា

សម្លេងឈូសស្នោរនៅក្បែនអគារពណ៌សមួយដែលធ្វើ ដោយកុមារា កុមារី ៣-៤នាក់ យ៉ាងញាប់ដៃញាប់ជើង និងដោយគ្មានការនឿយហត់ក្នុងថ្ងៃឈប់សំរាករបស់ពួកគេ ដែលនៅជុំវិញព័ទ្ធទៅដោយដើមឈើ និងផ្កាចម្រុះពណ៌ប្រកបដោយទិដ្ឋាធំទូលាយ គួរឱ្យចង់រស់នៅ។ កុមារីគន្ធា អាយុ ១២ឆ្នាំ ក្រោមសម្លៀកបំពាក់អាវពណ៌ស សំពត់ពណ៌ខៀវ ក្នុងទឹកមុខស្រស់ស្រាយបាននិយាយថា: "ខ្ញុំមកនៅក្នុងមណ្ឌលនេះ អស់រយៈពេលប្រហែល ៤ឆ្នាំហើយ"។ នាងបានបន្តថា នាងមានស្រុកកំណើតនៅឯខេត្តកំពង់ស្ពឺ និងមានបងប្អូន ៥នាក់ តែនាងមកនៅទីនេះតែម្នាក់ឯងទេ ដោយសារ នាងមានជំងឺពិស។ នៅទីនេះនាងមានសេចក្តីសប្បាយរីករាយដោយសារមានមិត្តភ័ក្តិច្រើនរាប់អាន និងស្រលាញ់នាង។

ក្នុងដៃកាន់សៀវភៅ ខណៈពេលដែលមិត្តភ័ក្តិជាច្រើនទៀតកំពុងលេងលោតកៅស៊ូ យ៉ាងសប្បាយ កុមារីស្រីណុច ដែលទើបតែមានវ័យ ១២ឆ្នាំ ហាក់ដូចជាមិនយកចិត្តទុកដាក់នឹងការលេងរបស់មិត្តនាងឡើយ។ នាងអង្គុយនៅជ្រុងម្ខាងនៃទូដាក់សៀវភៅ និងចាប់កាន់សៀវភៅរឿងមួយក្បាលមកអានយ៉ាងយកចិត្តទុកដាក់។ ស្រីណុចបានថ្លែងដោយសម្លេងយ៉ាងស្រទន់ថា: "ខ្ញុំ និងប្អូនរបស់ខ្ញុំជាក្មេងកំព្រាឪពុកម្តាយតាំងពីតូច តែមានតាយាយចិញ្ចឹមថែរក្សា"។ នាងបន្តថា ពីមុននាងត្រូវបានអ្នកភូមិមើលងាយថា នាងធ្វើអ្វីមិនកើត ពីព្រោះនាងជាមនុស្សពិការ។ ពេលនោះនាងមានការតូចចិត្ត ប៉ុន្តែឥលូវនាងក្លាហានឡើងវិញ បន្ទាប់ពីបានអង្គការជួយឱ្យនាងបានរៀនសូត្រ និងនាងអាចធ្វើអ្វីៗ បានដូចគេឯងដែរ។ កុមារីតូចពិការខ្នង (គមខ្នង) គួរឱ្យសង្វេគក្រៃលែងរូបនេះ បានបង្ហាញចំណាប់អារម្មណ៍របស់នាងថា នាងសប្បាយចិត្តដោយគ្មាននរណាមើលងាយនាងទៀតឡើយ និងនៅពេលអនាគត នាងចង់ក្លាយទៅជាគ្រូបង្រៀនមួយរូបដ៏ល្អ។

អ្នកស្រីសំណាង អាយុ៤៧ឆ្នាំ ដោយទឹកមុខញញឹមរាក់ទាក់បានឱ្យដឹងថា: "ដោយការស្រលាញ់ និងអាណិតដល់ក្មេងៗទាំងនេះ ទើបខ្ញុំសម្រេចចិត្តមកធ្វើការជាមួយពួកគេ"។ អ្នកស្រីបានចំណាយពេលអស់ ៨ឆ្នាំមកហើយ ក្នុងការរស់នៅជាមួយក្មេងៗដ៏គួរឱ្យអាណិតទាំងនេះ។ ក្នុងកាយវិការទំនងជាអៀនបន្តិច អ្នកស្រីបន្តថា ជាធម្មតា ការធ្វើការជាមួយក្មេងពិការ គឺមិនមានភាពងាយស្រួលប៉ុន្មានទេ ដោយសារគាត់ពុំសូវជាចេះកាយវិការភាសាគ។ ប៉ុន្តែនេះមិនមែនជាបញ្ហាធំសម្រាប់ស្ត្រីមេម៉ាយរូបនេះឡើយ។

កញ្ញាគឹម ផល្លា ជាអ្នកមើល និងអប់រំក្មេងៗបានឱ្យដឹងថា: "ក្មេងៗដែលយកមកចិញ្ចឹមនៅទីនេះ គឺមានអាយុពី៨-១៨ឆ្នាំដែលពួកគេភាគច្រើនត្រូវបានបុគ្គលិកនៃអង្គការនាំមកពីគ្រួសារ ដែលក្រីក្រ ជីវភាពខ្វះខាត មិនមានសមត្ថភាពទៅសាលារៀន"។ រីឯ កញ្ញាស្រី នាង ជាអ្នកមើលការខុសត្រូវក្មេងៗពិការ មណ្ឌលពន្លឺនៃមេត្តា មានប្រសាសន៍ឱ្យដឹងថា: "អង្គការទទួលក្មេងមកចិញ្ចឹម ព្រោះអង្គការមានឆន្ទៈមួយថា បើទុកក្មេងៗពិការនៅផ្ទះនោះ ពួកគេមិនបានធ្វើអ្វីសោះក្នុងជីវិត ប្រៀបដូចជាជនពិការអនាថា។ ដូច្នេះយើងបង្កើតកម្មវិធីនេះជួយជនពិការ ដើម្បីឱ្យពួកគេទទួលបានការអប់រំ និងបានចូលរួមក្នុងសង្គម"។ កញ្ញាបន្តថា ក្រុមការងាររបស់ខ្លួនមានការលំបាកបន្តិច ក្នុងការនាំក្មេងមកទីនេះ ព្រោះឪពុកម្តាយក្មេងមិនមានការទុកចិត្តដោយខ្លាច ពួកគាត់ជាអ្នកជួញដូរក្មេង ជាហេតុដែលធ្វើឱ្យពួកគាត់មានការលំបាក។

មុំ គន្ធា

**មណ្ឌលពន្លឺនៃមេត្តា**

ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការជេស៊ូត ដែលបង្កើតនៅឆ្នាំ១៩៩៧ ដោយបងស្រីម៉ារីអាដែលជនជាតិបារាំង ទទួលយកក្មេងពិការប៉ូលីយ៉ូ ពិការភ្នែកគ-ថ្លង់ និងគ្រោះថ្នាក់ដោយសារមីន។ កុមារដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការមាន: នៅក្នុងមណ្ឌល ចំនួន១៩នាក់ នៅអង្គការគ្រួសារថ្មីមាន ២០នាក់ និងនៅតាមសហគមន៍មាន ៤នាក់។ ពួកគេមកពីខេត្តកណ្តាល កំពងធំ កំពង់ចាម តាកែវ កំពត និងភ្នំពេញមានអាយុពី ៨-១៨ឆ្នាំ និងឱ្យរៀនពីថ្នាក់ទី១ ដល់ទី៧។ ការចំណាយក្នុង ១ខែ គឺ ៣៥ដុល្លារក្នុងម្នាក់។

# ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ជាគ្រឹះនៃជំនឿ

**បុណ្យចម្លងជាប្រពៃណីជនជាតិអ៊ីស្រាអែលតាំងពីដើមរៀងមកដើម្បីអរព្រះគុណព្រះជាម្ចាស់ ដែលបានរំដោះពួកគេចេញពីស្រុកអេស៊ីប។ យើងជាគ្រីស្តបរិស័ទ គោរពព្រះយេស៊ូដែលសុគតលើឈើឆ្កាង និងព្រះអង្គមានព្រះជន្មឡើងវិញដ៏រុងរឿង។**



Photo: L. Sovanna

រូបភាពឯកសាររបស់ អ្នកនាំសារ : ពិធីព្រះពរភ្លើង

"ព្រះជាម្ចាស់ បានប្រោសលោកយេស៊ូ អ្នកស្រុកណាសារ៉ែត ដែលគេបានឆ្កាង និងសម្លាប់ចោលយ៉ាងសែនអាម៉ាស់ឱ្យរស់ឡើងវិញ"។ នេះជាដំណឹងដ៏ប្រសើរថ្លៃថ្លាសម្រាប់យើងទាំងអស់គ្នា។ ដោយសារការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូនេះ ទើបមានអ្នកស្ម័គ្រចិត្តដើរតាម និងទទួលជឿថា "ព្រះអង្គគឺពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន"។

ព្រះសហគមន៍ប្រារព្ធពិធីនេះ ជារៀងរាល់ឆ្នាំ។ លោកសុគន្ធ មកពីព្រះសហគមន៍ កោះរកា ភូមិភាគកំពង់ចាម បានចាប់អារម្មណ៍ថា : "នេះជាឱកាសមួយល្អប្រសើរដើម្បីរំលឹកដល់ព្រះយេស៊ូដែលបានសុគត ហើយព្រះជាម្ចាស់ប្រោសទ្រង់ឱ្យមានព្រះជន្មឡើងវិញ"។ លោកបានបញ្ជាក់ថា ព្រះយេស៊ូជាស្ពានចម្លងយើងទៅរកព្រះបិតា ធ្វើឱ្យយើងមានទំនាក់ទំនងជាមួយព្រះបិតា។ ដោយសារព្រះយេស៊ូសុគត យើងបានរួចផុតពីនឹមនៃវិន័យ ជំនឿលើវត្ថុស័ក្តិសិទ្ធិ អារក្ស អ្នកតា-ល- គឺដោយសារព្រះយេស៊ូសុគត ធ្វើឱ្យយើងមាននូវសេរីភាព។ តែលោកបានសង្កត់ធ្ងន់ដោយ លើកពីលិខិតរបស់លោកប៉ូល ដែលបានសរសេរថា : "កុំយកសេរីភាពធ្វើជាលេស"។

រីឯលោកវង ធីម ជាគ្រីស្តបរិស័ទនៅព្រះសហគមន៍កំពង់ធំ គូសបញ្ជាក់ដែរថា បុណ្យចម្លង គឺរម្លឹកការដែលព្រះជាម្ចាស់ប្រោសព្រះយេស៊ូគ្រីស្ត ឱ្យមានព្រះជន្មឡើងវិញ តាមរបៀបថ្មី គឺតាមព្រះវិញ្ញាណដ៏វិសុទ្ធ។ បើតាមជំនឿយើងជាគ្រីស្តបរិស័ទ ព្រះយេស៊ូសុគតសម្រាប់យើងទាំងអស់គ្នា ដែលនាំឱ្យយើងទទួលបានសេរីភាព យ៉ាងបរិបូរ។ លោកបានសង្កត់ធ្ងន់ថា ប្រសិនព្រះជាម្ចាស់មិនប្រោសព្រះយេស៊ូ ឱ្យមានព្រះជន្មរស់ឡើងវិញទេ នោះគឺគ្មានអ្នកជឿ និងដើរតាមព្រះអង្គដូចសព្វថ្ងៃនេះទេ។ មនុស្សយើងម្នាក់ៗ កំពុងស្វែងរកបរមសុខខាងផ្លូវវិញ្ញាណ សម្រាប់ជីវិតគេ។ សម្រាប់ថ្ងៃអនាគត លោកក៏ជឿថា លោកនឹងរស់ឡើងវិញជាមួយព្រះយេស៊ូដែរ ដោយ "រួមស្លាប់រស់ជាមួយព្រះយេស៊ូ" ដោយសារអគ្គសញ្ញាជ្រមុជទឹកដែលលោកបានទទួល។

នៅត្រង់ចំនុចខាងលើនេះ លោកគ្រូគង្វាលប៉ូល តារា មកពីព្រះវិហារ សេចក្ដីមេត្តាករុណានៃព្រះគ្រីស្ត ក៏យល់ស្របផងដែរដោយបានបង្ហាញជំនឿថា : "យើងជឿលើព្រះអង្គដែលមានព្រះជន្មរស់ឡើងវិញ មិនមែនជឿលើមនុស្សដែលស្លាប់បាត់នោះឡើយ"។ លោកគ្រូមានប្រសាសន៍ទៀតថា នៅថ្ងៃអាទិត្យនោះ មានការអធិដ្ឋានពិសេសដើម្បីសម្អាតចិត្តគំនិតទទួលព្រះជន្មរស់ឡើងវិញដូចអង្គព្រះយេស៊ូ ដោយយើងកប់ចោលនិស្ស័យចាស់ ក្នុងផ្នូររួមជាមួយព្រះយេស៊ូ ទទួលយកជីវិតថ្មីដូចព្រះយេស៊ូ ហើយក្នុងអង្គប្រជុំ មានការអធិប្បាយពិសេស ដែលទាក់ទងទៅនឹងការរស់ឡើងវិញ នៃព្រះយេស៊ូ ដោយលើកនូវ ខ ក្នុងគម្ពីរជាច្រើន មកធ្វើជាភស្តុតាង។

បើយើងនិយាយអំពីពិធីបុណ្យនេះ នៅក្នុងព្រះសហគមន៍ ឬគ្រីស្តសាសនា ថ្ងៃដែលព្រះយេស៊ូមានព្រះជន្មរុងរឿងឡើងវិញ ជាថ្ងៃដ៏សំខាន់ និងជាគ្រឹះនៃជំនឿផងដែរ។ សព្វថ្ងៃ អ្វីដែលបញ្ជាក់ពីវត្តមានរបស់ព្រះអង្គ គង់នៅជាមួយយើង គឺទៀនព្រះជ័យ ដែលជានិមិត្តរូបនៃព្រះជន្មគង់នៅ អស់កល្បជានិច្ច ដូចព្រះយេស៊ូមានព្រះបន្ទូលថា : "កាលណា២ ឬក៏បីនាក់មកជួបជុំគ្នា នោះក៏មានខ្ញុំដែលឋិតនៅជាមួយដែរ"។

លី សុវណ្ណា

## បុណ្យចម្លងជាគ្រឹះនៃជំនឿ

នាបុណ្យចម្លងខាងមុខ លោកបូជាចារ្យនឹងនាំគ្រីស្តបរិស័ទឱ្យចាប់អារម្មណ៍កាន់តែខ្លាំងដោយឱ្យគេធ្វើសកម្មភាពខ្លះៗ។ នៅកោះរកា តាំងពីចាប់ផ្ដើមនៃវដ្ដអប់រំពិសេស គ្រីស្តបរិស័ទត្រូវបានដាស់តឿនឱ្យយកចិត្តទុកដាក់អធិដ្ឋានដោយធ្វើឡើងរាល់ថ្ងៃ។ ជំនឿយើង គឺរួមស្លាប់រួមរស់ជាមួយព្រះយេស៊ូដោយអគ្គសញ្ញាជ្រមុជទឹក។ នៅកំពង់ធំឆ្នាំនេះ នឹងមានប្រារព្ធពិធីធំជាងឆ្នាំមុនដើម្បីផ្ដល់អត្ថន័យសំខាន់ដល់ពិធីបុណ្យ។





# ចិញ្ចឹមជ្រូក

**ជ្រូកគឺជាសត្វមួយ ដែលប្រជាកសិករយើងនិយមចិញ្ចឹមជាលក្ខណៈគ្រួសារដើម្បីផ្គត់ផ្គង់ជីវភាពឱ្យកាន់តែប្រសើរ ដូច្នេះតើពួកគាត់ត្រូវចិញ្ចឹមតាមបច្ចេកទេសយ៉ាងណាដើម្បីឱ្យទទួលបានផលល្អ?**

តើយើងត្រូវចិញ្ចឹមជ្រូកយ៉ាងម៉េចដើម្បីបានឆាប់ធំ? លោកបណ្ឌិតមាយ ប្រមូល អ្នកទទួលបន្ទុកផ្នែកគាំទ្របច្ចេកទេសនៃអង្គការ ស៊ីដាក បានប្រាប់អំពីរបៀបចិញ្ចឹមជ្រូកថា :

### ការជ្រើសរើសពូជ

យើងអាចសម្គាល់ដឹងថា វាគឺជាជ្រូកល្អដោយយកគំចំណាំទៅលើចំនុចមួយចំនួន ដូចជា ជ្រូកមានដងខ្លួនវែង ជើងមាំត្រង់ល្អ មានខ្នងកោងបន្តិច និងរាងសង្ហា។ ប្រសិនបើជា ជ្រូកមេគឺត្រូវឱ្យដោះរបស់វា មាន៦គូ ត្រគាតវាសាយ និងកវែង។ ប្រការដែលល្អ គឺគួរតែទិញជ្រូកនៅក្នុងស្រុក ពីព្រោះវាស៊ាំទៅនឹងអាកាសធាតុរួចជាស្រេច ជៀសវាងការឈឺងាប់។

### ការធ្វើទ្រុង និងផ្ដល់ចំណី

ទ្រុងត្រូវឱ្យមានខ្យល់ចេញចូលល្អ នៅលើទីទួល មិនដក់ទឹក ដោយអាចបង្ហូរកាកសំណល់ ប្រក់ស្លឹក ឬអាចចាក់សាប ជាដើម។ ប្រសិនបើយើងដាក់វានៅកន្លែងក្ដៅ ឬក៏ប្រក់ដំបូលក្ដៅ អាចធ្វើឱ្យវាឈឺ និងមិនស៊ីចំណី។

ចំណីជ្រូក មាន ៤ប្រភេទ គឺចំណីថាមពល (កន្ទក់ ចុងអង្ករ ទឹកស្ករ ឬកាកដូងជាដើម)។ ចំណីនេះត្រូវមានបរិមាណតិចជាងចំណីវីតាមីន)។ ចំណីវីតាមីនមានដូចជា ស្លឹកកន្ទំថេត ចកបាយទា រុក្ខជាតិផ្សេងៗទៀត កំទេចត្រី កាកសំណល់ត្រីម្សៅត្រី ឬក៏សណ្ដែកសៀងដែលល្អបំផុត)។ ចំណីប្រូតេអ៊ីន និងចំណីជាតិរ៉ែ (សំបកខ្យង-ខ្ចៅដោយបុកឱ្យម៉ត់)។ ចំណី ៤ប្រភេទនេះ បើឱ្យជ្រូកស៊ីបានត្រឹមត្រូវ វាមានគុណភាពល្អជាងចំណីទិញនៅផ្សារ។ ត្រូវតែដាក់ទឹកឱ្យជ្រូកផឹកជាទៀងទាត់ព្រោះបើខ្វះជាតិទឹក ការលូតលាស់របស់វាក៏តិចដែរ។

### ការថែទាំ

យើងត្រូវថែទាំសំអាតទ្រុង ឱ្យស្អាត។ ពេលដែលយើងទិញជ្រូកយកមកដំបូង ត្រូវចងជ្រូកនៅខាងក្រៅទ្រុងសិនដើម្បីមើលថា តើវាមានផ្ទុកជំងឺ ឬអត់? នៅពេលដែលយើងលក់ជ្រូកអស់ ត្រូវលាងសំអាតទ្រុង បាចកំបោរស ឬស្រោចទឹកក្ដៅមុននឹងដាក់ជ្រូកថ្មីចូល និងចាក់ថ្នាំបង្ការ។

មុំ គន្ធា

## កន្លែងសិក្សា

ប្រសិនបើលោកអ្នកចង់សិក្សាអំពីរបៀបបច្ចេក-ទេសនៃការចិញ្ចឹមសត្វគ្រប់ប្រភេទ គឺមាននៅមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (ស៊ីដាក) ឬអាចអញ្ជើញបុគ្គលិកស៊ីដាកទៅបង្រៀនដល់កន្លែងដោយតម្លៃសមរម្យ។ ទំនាក់ទំនងទូរស័ព្ទ : ០១២ ៣២៥៧១០។



Photo: CEDAC

ជ្រូកដែលប្រជាកសិករចិញ្ចឹមតាមបច្ចេកទេសដែលបង្ហាត់បង្ហាញដោយអង្គការស៊ីដាក

## អន្តរជាតិ

# សម្ដេចប៉ាបតែងតាំងកាឌីណាល់ថ្មី ១៥អង្គ

**កាលពីថ្ងៃសុក្រទី១៤ មីនា សម្ដេចប៉ាបបេណេឌីកតូ ទី១៦ តែងតាំងកាឌីណាល់ថ្មីចំនួន១៥អង្គ នៅក្នុងការប្រជុំពីមុខងារសម្ដេចប៉ាបលើកទី១ នៅបុរីវ៉ាទីកង់។**

ក្នុងចំណោមកាឌីណាល់ ដែលត្រូវតែងតាំងទាំងអស់ គឺមានអគ្គអភិបាលមកពីហុងកុងម្នាក់ ដែលជាអ្នកឃោសនាយ៉ាងសកម្មមួយពីសេរីភាពខាងសាសនានៅប្រទេសចិន និងក៏ជាកាឌីណាល់ជនជាតិចិនដំបូងគេបំផុត។ ការតែងតាំងបន្ថែមនេះធ្វើឱ្យចំនួនកាឌីណាល់កើនរហូតដល់ទៅ ១៩៣អង្គ។ តាមអ្នកយកព័ត៌មាន ប៊ីប៊ីស៊ីបានឱ្យដឹងដែរថា ការតែងតាំងលោកអគ្គអភិបាលយ៉ូសែប ហ្សេន (Joseph Zen) នៃទីក្រុងហុងកុងជាសញ្ញាប្រាប់ឱ្យដឹងថា សេរីភាពខាងសាសនាជាចំនុចសំខាន់ជាងគេរបស់សម្ដេចប៉ាប។ សម្ដេចប៉ាបក៏បានមានបន្ទូលថា កាឌីណាល់ថ្មីនឹងឆ្លុះបញ្ចាំងឱ្យឃើញ ពីភាពជាសកលរបស់ព្រះសហគមន៍កាតូលិក។

កាឌីណាល់ថ្មី១៥អង្គនេះ មកពីព្រះសហគមន៍កាតូលិក ១១ ប្រទេស ដូចជា អគ្គអភិបាលនៃទីក្រុងការ៉ាកាសនៃប្រទេសវេណេហ្សូអេឡា ក្រុងម៉ានីលប្រទេសភីលីពីន ក្រុងសេអ៊ូលនៃប្រទេសកូរ៉េ និងទីក្រុងតូឡេដូនៃប្រទេសអេស្ប៉ាញ។

សុខ ពង្សមេត្រី

## រូបទាំងពីរខាងក្រោមនេះមានចំនុចខុសគ្នា ១២ចំនុច។ សូមប្រិយមិត្តសាកល្បង ស្វែងរកទៅមើលថាតើចំនុចទាំងនោះនៅទីណាខ្លះ?





# កាត់សក់

**សក់ គឺជាផ្នែកមួយនៃសោភ័ណភាពរាងកាយ។ សម្រាប់បុរសភាគច្រើន ការទៅកាត់សក់ដើម្បីឱ្យបានសមរម្យគឺជាកិច្ចមួយដ៏ចាំបាច់។ ជាងកាត់សក់មានតួនាទីលើកសម្ផស្សរបស់គេដើម្បីភាពថ្លៃថ្នូរ។**



Photo: P. Samphy

ជាងខំផ្ចិតផ្ចង់កាត់សក់ឱ្យបានស្អាតដើម្បីទាក់ម៉ូយឱ្យចូលបានច្រើន

ដៃឆ្វេងកាន់ក្រាសសិត ដៃស្តាំកាន់ត្រង់ដឺ គេកំពុងតែឈូសឆាយជើងសក់របស់ភ្ញៀវ ដោយផ្ចិតផ្ចង់ធ្វើយ៉ាងណាឱ្យសក់ដែលកំពុងតែកាត់មានភាពស្អាត និងសាកសម។

លោកសុង ដាក ជាមេជាងកាត់សក់មួយ នៅក្នុងហាងមួយទល់មុខនឹងរង្វង់មូលក្រុងតាខ្មៅ ខេត្តកណ្តាល បាននិយាយថា ការកាត់សក់នេះមានជួបលំបាកគួរសមដែរ។ ពេលភ្ញៀវគេសុំឱ្យយើងកាត់សក់ គឺយើងត្រូវគិតកាត់យ៉ាងណា ដោយប្រុងប្រយ័ត្ន និងឱ្យបានស្អាត ពីព្រោះបើយើងកាត់ខុសនោះយើងមិនអាចទិញសក់ខុសនោះបានទេ។

តាមប្រសាសន៏បន្តរបស់មេជាងរូបនេះ បានបញ្ជាក់ទៀតថា ដើម្បីឱ្យរបររកស៊ី មានភាពរីកចម្រើន យើងត្រូវព្យាយាមកាត់សក់ដោយបំពេញចិត្តភ្ញៀវចំពោះម៉ូដណាដែលគេប្រាប់យើង។ ពេលខ្លះយើងអាចសំណូមពរថា បើគេកាត់ម៉ូដតាមយើងប្រាប់ ទើបវាត្រូវម៉ាច់ សាកសមទៅនឹងទម្រង់មុខ និងក្បាលរបស់គេ។ យើងត្រូវបង្កបរិយាកាសឱ្យភ្ញៀវសប្បាយចិត្តផងដែរ ដោយយើងកុំធ្វើមុខក្រញូវ ខឹងអ្វីតិចតួច ក៏ត្រូវធ្វើមុខញញឹមដែរ ហើយអរគុណគេក្រោយពីទទួលលុយមុននឹងគេចេញទៅ។ លើសពីនេះយើងត្រូវណែនាំកូនជាងយើងឱ្យបំពេញចិត្តភ្ញៀវ ឱ្យបានដូចជាយើងផងដែរ។

ជាទូទៅជាងកាត់សក់ត្រូវតែស្វែងយល់អំពីម៉ូដថ្មីៗដើម្បីរត់ឱ្យទាន់សម័យនិយម។ ម៉ូដសក់ទាំងនេះ គេអាចមើលតាមតួអង្គនៅក្នុងទូរទស្សន៏ តាមរឿងចិន ថៃ និងរឿងហូលីវូដ ឬមួយមើលតាមកាសែត ឬទស្សនាវដ្តីម៉ូដសក់ជាដើម។

ចំណូលនៅក្នុងហាងកាត់សក់ បានច្រើន ឬតិច អាស្រ័យលើចំនួនអតិថិជន។ លោកសុង ដាក ពន្យល់ថា នៅតាមហាងនីមួយៗ ថ្លៃឈ្នួលដែលគេយកពីអតិថិជន គឺមិនដូចគ្នាទេ វាអាស្រ័យទៅលើការរៀបចំហាងឱ្យបានស្អាត និងក្រអូប ឱ្យសមនឹងតម្លៃ។ ជាក់ស្តែងហាងរបស់លោក កាត់សក់ធម្មតាគឺយកពីភ្ញៀវ ក្នុងម្នាក់ ២០០០រៀល។

លោកសុង ដាក គូសបញ្ជាក់ថា យើងអាចទៅរៀនកាត់សក់តាមរយៈមេជាងនៅហាង ឬក៏សាលាផ្សេងៗ ដែលបង្រៀនជំនាញនេះ។ ហើយដើម្បីឱ្យបានពូកែយើងត្រូវមានការតស៊ូ ដោយគិតថា ការងារនេះជាឆ្នាំងបាយរបស់យើង។

ផាត សំភី

### សាលាបង្រៀនកាត់សក់

សាលាបង្រៀនកែសម្ផស្សភ្នំពេញ បង្រៀនកាត់សក់បុរស មួយវគ្គ៥០$ រៀនរយៈ២ខែ និងបន្តរហូតដល់ចេះ ទូរស័ព្ទ: ០១២ ៧០១៧៧១។

សាលាកេត វ៉ាឌី មានបង្រៀនកាត់សក់មួយវគ្គតម្លៃ ៥០$ រៀនរយៈពេល ៤ ឬ៥ខែ និងរហូតដល់ចេះ ទូរស័ព្ទ: ០១២ ៨៧៣៦១។

សាលាទាំងពីរ នឹងមានចេញសញ្ញាប័ត្របញ្ជាក់ជូននៅពេលរៀនចប់។



# ការរក្សាខ្លួនពេលមានផ្ទៃពោះ

**មុននឹងប្រសូតបុត្រ ស្ត្រីមានផ្ទៃពោះត្រូវការស្វែងយល់នូវរបៀបរក្សាខ្លួនដើម្បីការពារសុខភាពរបស់ខ្លួន និងទារកដែលនឹងប្រសូតនាពេលខាងមុខឱ្យមានសុខភាពល្អ។**

ចាប់ពីពេលមានទំងន់ រហូតដល់សប្តាហ៍ទី១៣ យើងហៅថា រយៈចាញ់ ស្ត្រីខ្លះមានអាការៈ ដូចជាក្អួតចង្អោរ និងមានការអស់កម្លាំងយ៉ាងខ្លាំង។ នេះជារយៈពេលគ្រោះថ្នាក់បំផុត។ ស្ត្រីត្រូវតែទៅធ្វើការពិគ្រោះជាមួយនិងពេទ្យជំនាញដើម្បីទទួលការណែនាំអំពីរបៀបថែរក្សាខ្លួន។

ចាប់ពីសប្តាហ៍ទី១៣ទៅ អាការៈចាញ់មានការថយចុះ ប៉ុន្តែស្ត្រីគួរតែទៅមណ្ឌលសុខភាពឱ្យបានទៀងទាត់ដែរ ដើម្បីឱ្យពេទ្យមានលទ្ធភាពតាមដានសភាពផ្ទៃពោះ។

នៅពេលមានផ្ទៃពោះ ស្ត្រីអាចជួបប្រទះនូវសញ្ញាគ្រោះថ្នាក់ផ្សេងៗ មានដូចជា ការធ្លាក់ឈាម ក្អួតយ៉ាងខ្លាំង កើតរោគហើម ឬក៏សម្ពាធឈាមឡើងខ្លាំង ដែលខ្មែរហៅថា ព្រាយក្រឡាភ្លើង-ល-។ ដូច្នេះអ្នកនៅក្បែរ ឬសាច់ញាតិ ត្រូវរកមធ្យោបាយដើម្បីបញ្ជូនគាត់ទៅកាន់មន្ទីរពេទ្យ ពីព្រោះជាកន្លែងដែលអាចធ្វើការសង្គ្រោះបន្ទាន់បាន។

ស្ត្រីមានផ្ទៃពោះគួរញុំាអាហារណាដែលសំបូរទៅដោយជាតិវីតាមីន និងអាហារដែលមានជាតិប្រ៉ូវ មានដូចជា សាច់ ស៊ុតថ្មើម ត្រី ទឹកដោះ បន្លែ ផ្លែឈើ-ល- ហើយការបរិភោគនេះ គួរតែហូប ម្តងៗ ល្មមៗ តែច្រើនដង ក្នុងមួយថ្ងៃ។

ស្ត្រីមានផ្ទៃពោះគួរជៀសវាង ការឈរ ឬក៏អង្គុយយូរពេក។ ស្ត្រីគួរសំរាកឱ្យបានច្រើន យ៉ាងតិច ៨ម៉ោង នៅពេលយប់។ ពេលជិតសំរាល ពោះធំខ្លាំង ស្ត្រីគួរសំរាកផ្អៀងទៅខាងស្តាំដើម្បីជៀសវាងការធ្វើឱ្យមានអាការៈទល់លាមក។

ដើម្បីកាត់បន្ថយគ្រោះថ្នាក់ ពេលមានផ្ទៃពោះ ទាំងស្ត្រី និងទាំងបុរស គួររៀបចំផែនការគ្រួសារដោយរក្សាគម្លាតពីកូនមួយទៅកូនមួយ ឱ្យបាន៥ឆ្នាំ។ នេះជាការល្អ។ តែបើយ៉ាងតិចណាស់ក៏ ៣ឆ្នាំដែរ ហើយស្ត្រីជៀសវាងមានផ្ទៃពោះ មុនអាយុ ១៨ឆ្នាំ និងក្រោយអាយុ ៣៥ឆ្នាំ។

ផាត សំភី



Photo: P. Samphy

វេជ្ជបណ្ឌិតស្រ៊ុន លី នៃអង្គការដើម្បីភាពញញឹមនៃកុមារ

### ចាក់ថ្នាំបង្ការ

ស្ត្រីមានផ្ទៃពោះត្រូវតែទៅចាក់ថ្នាំការពារជំងឺតេតាណូសឱ្យបាន ២ ដងមុនពេលសំរាលដើម្បីការពារកូនពីជំងឺនេះដែលអាចឆ្លងតាមរយៈការប្រើសំភារៈដែលមិនបានរម្ងាប់មេរោគនៅពេលសំរាល។

# លោកអភិបាលអេមីល:“ខ្ញុំរស់នៅដោយព្យាយាមតាមគំរូព្រះយេស៊ូ”


Photo: S. Metrey

លោកអេមីល ដេតម្ប ដែលជាអភិបាលភូមិភាគភ្នំពេញ

**លោកអភិបាលអេមីល ដេតម្ប ជាជនជាតិបារាំង និងបានមកនៅបម្រើបងប្អូនគ្រីស្តបរិស័ទកម្ពុជាតាំងពីឆ្នាំ១៩៦៤ ជាមួយស្មារតីមុះមុត និងពុំខ្លាចនឿយហត់។**

លោកអភិបាល ដែលបានមករស់នៅកម្ពុជា ជាង ២០ឆ្នាំ បានមានប្រសាសន៍ថា: “ខ្ញុំស្គាល់ប្រទេសកម្ពុជាតាមរយៈការសិក្សា ដែលពេលនោះកម្ពុជាឋិតនៅក្រោមអាណានិគមបារាំង”។ លោកក៏បន្តថា លោកតែងចង់មកកម្ពុជាឆាប់ៗ ព្រោះនេះ គឺជាទឹកដីដែលព្រះជាម្ចាស់ចាត់ឱ្យមក។

មុនឆ្នាំ១៩៧៥ លោកជាសាស្ត្រាចារ្យផ្នែកទស្សនវិជ្ជាមួយរូបនៅទេវវិទ្យាល័យក្នុងទីក្រុងភ្នំពេញ។ លោក បានទទួលអគ្គសញ្ញា តែងតាំងធ្វើជាលោកអភិបាលនៅថ្ងៃទី៥ តុលា ១៩៩៧ បន្ទាប់ពីលោកអភិបាល អ៊ីវ រ៉ាមូស សុំលាឈប់ពីតំណែង ដោយឱ្យសម្តេចប៉ាបយ៉ូហាន ប៉ូល ទី២ ជ្រើសរើសអភិបាលថ្មីនៅរាជធានីភ្នំពេញជំនួសរូបលោក។

ដែទាំងពីរចាប់បញ្ចូលគ្នា លោកបន្តថា: “ខ្ញុំយល់ព្រមដែលព្រះសហគមន៍ឱ្យខ្ញុំធ្វើជាអភិបាល។ ខ្ញុំមិនសូវប្រសប់ប៉ុន្មានទេ ប៉ុន្តែ ខ្ញុំសុខចិត្តបូជាជីវិតបម្រើបងប្អូនក្នុងឋានៈខ្ញុំជាអភិបាល”។ មុខងារអភិបាលនេះគឺជាមុខងារមួយដ៏ធ្ងន់ធ្ងរ តែលោកនៅតែរីករាយនឹងទទួលទាំងដឹងថា ខ្លួនមិនសូវមានសមត្ថភាព ឆ្លើយតបសេចក្តីត្រូវការ និងសំណូមពររបស់គេទាំងអស់ឡើយ។

លោកអភិបាលអេមីល បានបន្ថែមថា លោកគឺជាអ្នកបម្រើ។ លោកតែងតែសុំគ្រីស្តបរិស័ទឱ្យជួយដើម្បីជាប្រយោជន៍ព្រះសហគមន៍ និងចំពោះព្រះរាជ្យព្រះជាអម្ចាស់នៅប្រទេសកម្ពុជា។

ស្ថិតក្នុងវ័យ ៧០ឆ្នាំ ប្លាយ លោកអភិបាលរូបនេះចូលចិត្តចែករំលែកសេចក្តីស្រឡាញ់ និងក្តីសង្ឃឹមដល់មនុស្ស។ នេះគឺជាគោលបំណងនៃជំនឿដែលលោកមានតាំងពីតូចមក ហើយលោកក៏តែងរស់នៅយកតាមគំរូព្រះយេស៊ូដែលមានស្រាប់។

ទឹកមុខកំពុងញញឹម លោកក៏បានបន្តថា: “ខ្ញុំត្រូវបង្ហាញមុខស្រស់គ្រប់ពេល បើធ្វើមុខជូរ និងមានគេមកសួរ នេះដូចជាយើងមិនចង់ជួបមុខគេ។ ខ្ញុំជាអភិបាល មានន័យថា ជាអ្នកបម្រើប្រយោជន៍ព្រះសហគមន៍ និងបងប្អូនទាំងអស់”។

សព្វថ្ងៃនេះ លោកអភិបាលអេមីល ដេតម្ប គ្រប់គ្រងភូមិភាគព្រះសហគមន៍ភ្នំពេញ មើលថែរក្សាគ្រីស្តបរិស័ទ ជួយដល់ការអប់រំ និងរៀបចំកម្មវិធីឱ្យមានបូជាចារ្យនៅកន្លែងផ្សេងៗ។ លោកក៏ជាប្រធានអង្គការការីតាស់ ដែលជួយដល់ជនភៀសខ្លួន និងផ្តោតលើការអភិវឌ្ឍន៍ក្នុងសហគមន៍ ផងដែរ។ គម្រោងការលោកសម្រាប់ព្រះសហគមន៍គឺប្រមូលគ្រីស្តបរិស័ទឱ្យចូលរួមក្នុងអនុគណៈកម្មការទាំង៣ ហើយឱ្យព្រះសហគមន៍ ចាំបាច់ត្រូវចាប់អារម្មណ៍ទៅលើអ្នកក្រីក្រ ជនភៀសខ្លួន និងចាស់ជរា-ល-។ លោកអភិបាល អេមីល ដេតម្ប មានអារម្មណ៍ថា កម្ពុជាជាផ្ទះរបស់លោក ទោះបីលោកគឺជាជនបរទេសក៏ដោយ ក៏លោកនៅរហូតដល់ព្រះជាម្ចាស់សព្វព្រះរាជហឫទ័យ។

ហ៊ូ សុខធារី

## ព្រឹត្តិការណ៍នឹងមាន!

- ថ្ងៃ៥ មេសា: ពិធីប្រសិទ្ធពរលើប្រេងសម្រាប់អគ្គសញ្ញាផ្សេងៗ ម៉ោង៦ព្រឹក ដែលមានការចូលរួមពីបូជាចារ្យពីគ្រប់ព្រះសហគមន៍ រៀបចំធ្វើនៅផ្សារតូច។
- ថ្ងៃ៩ មេសា: ការប្រារព្ធពិធីបុណ្យចម្លងធ្វើនៅព្រះសហគមន៍កំពង់ចាមក្រុង។
- ថ្ងៃ៩ មេសា: បុណ្យហែស្លឹកនៅផ្សារតូច និងកំពង់សោម ដែលមានកម្មវិធីសម្តែងកាយវិការអំពីទុក្ខលំបាករបស់ព្រះយេស៊ូ។
- ថ្ងៃ១១ មេសា: សំណាក់ធម៌តេហ្សេរបស់យុវជន ១០០នាក់ នៅព្រះសហ-គមន៍ភូមិថ្មីនៅក្នុងភូមិភាគកំពង់ចាម។
- ថ្ងៃ១២-ថ្ងៃ១៣ មេសា: ពិធីបាចទឹកព្រះពរតាមផ្ទះគ្រីស្តបរិស័ទនៅកំពង់ចាម។
- ថ្ងៃ១៤ មេសា: ម៉ោង៨ព្រឹក ដើរលើផ្លូវព្រះឈើឆ្កាង និងពេលរសៀល ម៉ោង៤ គោរពទុក្ខលំបាកព្រះយេស៊ូ ដែលសោយទិវង្គត នៅព្រះសហគមន៍ផ្សារតូច។
- ថ្ងៃ១៤-ថ្ងៃ១៦ មេសា: បុណ្យចូលឆ្នាំខ្មែរនៅព្រះសហគមន៍កំពង់ចាម។
- ថ្ងៃ១៥ មេសា: បុណ្យជ្រមុជទឹកមនុស្សពេញវ័យ ១០នាក់ នាពេលរាត្រីបុណ្យចម្លង នៅព្រះសហគមន៍ផ្សារតូច។
- ថ្ងៃ១៨ មេសា: ប្រជុំគុម្ពលក្រុមប្រឹក្សាអន្តរសាសនាកម្ពុជាស្តីពីការអប់រំសាសនានៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យកម្ពុជា ដែលមានសាសនា៣ចូលរួម គឺគ្រីស្តសា-សនា (និកាយកាតូលិក និងប្រូតេស្តង់) ឥស្លាមសាសនា និងពុទ្ធសាសនាមាន (មហានិកាយ និងធម្មយុត្តិកនិកាយ)។
- ថ្ងៃ២០ មេសា: ប្រជុំអន្តរនិកាយនៅព្រះវិហារមេត្តាឱស នៅខេត្តកំពង់ចាម។
- ថ្ងៃ១ ឧសភា: សំណាក់ធម៌ក្រុមវ៉ាំងសង់ដឺប៉ូល ៥០នាក់ នៅកំពង់ចាម។

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៩២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ ហែរណាន់ ពីនីយ៉ា